# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុន
# ស្មាត អាស្យាតា ខូអិលធីឌី

IMPORTANT OF ACCOUNTANT IN COMPANY
SMART AXIATA CO., LTD

## ជំនាញ គណនេយ្យ

**រាជធានីភ្នំពេញ-ឆ្នាំ២០២៤**

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុន
# ស្មាត អាស្យាតា ខូអិលធីឌី

IMPORTANT OF ACCOUNTANT IN COMPANY
SMART AXIATA CO., LTD

**សាស្ត្រាចារ្យណែនាំ៖ ប៊ុន មករា**

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៤**

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**

**ប្រធានបទ៖ សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុន ស្មាត អាស្យាតា ខូអិលធីឌី**

| | |
|---|---|
| គណៈកម្មការវាយតម្លៃទី១ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត ស្រេង ផល្លា | ប៊ុន មករា |
| គណៈកម្មការវាយតម្លៃទី៣ | គណៈកម្មការវាយតម្លៃទី២ |
| បេក្ខបណ្ឌិត យ៉ាក វុទ្ធី | បេក្ខបណ្ឌិត មាស សំណាង |
| ប្រធានគណៈកម្មការវាយតម្លៃនិងជាប្រធាន មជ្ឈមណ្ឌលស្រាវជ្រាវ | គណៈកម្មការវាយតម្លៃទី៤ |
| បណ្ឌិត សេង សំអឿន | បេក្ខបណ្ឌិត យ៉ែម សុខហៀក |
| **នាយកវិទ្យាស្ថាន** | នាយិការងអចិន្ត្រៃយ៍ |
| **បណ្ឌិត ហេង វ៉ាន់ដា** | បណ្ឌិត ហ៊ូ គុជគន្ធលីនណា |

# អារម្ភកថា

(Impression)

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈ ពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជា គណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈ សំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់វិទ្យាស្ថាន វ៉ាន់ដាបានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធី សិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជា អនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ បានមកដល់ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើស នូវប្រធានបទមួយស្តីពី "**សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុនសេវាកម្ម Smart Axiata”** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យ យល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃសារៈសំខាន់របស់គណនេយ្យករ។ ក្រុមយើងខ្ញុំ សង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែក ក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀត ដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



១,អឿន ចាន់ធឿន

ID HS21/604



២,វទ ប៉ៃ

ID HS21/597



៣,ប៉ិល ម៉ាឡា

ID HS21/589



៤,គាត រតនា

ID HS21/596



៥,ណៅម ស្រីណា

ID HS21/607

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំ ជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **ម៉ុន មករា** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺ**អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមខ្ញុំបាទ នាងខ្ញុំ ជានិសិតស្សបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ " សារៈសំខាន់របស់គណនេយ្យករ ក្នុងក្រុមហ៊ុនសេវាកម្ម Smart Axiata " នេះគឺជាស្នាដៃរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះជាអត្ថបទស្រាវជ្រាវថ្មីសិទ្ធសាធ ដែលពុំមានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ............ខែ...........ឆ្នាំ.............ព.ស.២៥៦

ថ្ងៃទី.........ខែ...........ឆ្នាំ២០២៤

ហត្ថលេខាតំណាងក្រុម

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្រុមហ៊ុន Smart Axiata បានចាប់ផ្តើមដំណើរការក្នុងវិស័យទូរគមនាគន៍កម្ពុជា កាលពីខែកុម្ភៈ ឆ្នាំ ២០០៩ ក្រោមឈ្មោះ «Smart Mobile»។ ទោះជាការចាប់ផ្តើមដំបូងមានភាពសាមញ្ញ ក៏ដោយបន្តិចម្តងៗ ក្រុមហ៊ុនកាន់តែមានភាពលេចធ្លោ តាមរយៈគោលការណ៍អាជីវកម្មថ្មីៗ និងទំនើបដែលរួមមានតម្លៃសមរម្យ សេវាកម្មគួរឲ្យទាក់ទាញ និង្គយុទ្ធសាស្ត្រផ្តោតលើអតិថិជន។ ក្រុមហ៊ុន Smart Axiata Co., Ltd. ជាប្រតិបត្តិករទូរគមនាគមន៍ចល័តឈានមុនគេ ក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ន ក្រុមហ៊ុនបាននឹងកំពុងបម្រើអតិថិជនចំនួន ៨ លាននាក់ ស្ថិតក្រោមស្លាកសញ្ញា "Smart"។ Smart Axiata គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមេ មានឈ្មោះថា "Axiata Group Berhad" ដែលជាក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ធំជាងគេបង្អស់មួយក្នុងទ្វីបអាស៊ី។

ក្រោយពីបានសិក្សាស្រាវជ្រាវនេះ មានគោលបំណងក្នុងការស្វែងយលពី គោលនយោបាយ រចនាសម្ព័ន្ធ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនសេវាកម្ម Smart Axiata (ប្រវត្តរបស់ក្រុមហ៊ុន ចក្ខុវិស័យ បេសកកម្ម និងទស្សនៈវិស័យ) រចនាសម្ព័នរបស់ក្រុមហ៊ុនសេវាកម្ម Smart Axiata និងតួនាទីរបស់គណនេយ្យករ ក្នុងក្រុមហ៊ុន ក៏ដូចជាសារៈសំខាន់របស់គណនេយ្យករ។ អ្វីដែលចាំបាច់នោះគឺតួនាទី និងសារៈសំខាន់របស់គណនេយ្យករ ដែលត្រូវទទួលខុសត្រូវមួយក្នុងការកត់ត្រាចំណូល និងចំណាយរបស់ក្រុមហ៊ុនក៏ដូចជាការរៀបចំផែនការហិរញ្ញវត្ថុ ព្រមទាំងកត់ត្រាផងដែរ។ ក្រុមហ៊ុនត្រូវតែមានគណនេយ្យករដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវ ស្របតាមច្បាប់ និងបទបញ្ញាត្តិផ្សេងរបស់គណនេយ្យ។ ទន្ទឹមនឹងនេះដែរ សារៈសំខាន់របស់គណនេយ្យករ ដែលអាចជួយសម្រួលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យមានរបៀបរៀបរយ និងមានលំនឹង។ តាមវិធីសាស្ត្រខាងលើក្រុមហ៊ុន ក៏ទទួលបានធ្វើការវិភាគម្តងមួយចំណុចៗ យ៉ាងលម្អិត ដែលនាំឱ្យក្រុមហ៊ុនទទួលបាននូវគោលជំហរយ៉ាងរឹងមាំ និងយូរអង្វែងរហូតមកដល់សព្វថ្ងៃ។

ទោះបីជាយ៉ាងណាក៏ដោយក៏គណនេយ្យករ នៅតែមានចំណុចខ្វះខាតមួយចំនួនតូចដែលកើតឡើងទៅលើឯកសារមួយចំនួន និងកង្វះខាតផ្នែកបច្ចេកវិទ្យានៅពេលបំពេញតួនាទីហើយពេលសេវាកម្មមានការយឺតយ៉ាងក៏ដោយ ក៏គណនេយ្យនៅតែអាចផល្តល់ឱ្យក្រុមហ៊ុន នូវរបាយការណ៍ហិរញ្ញវត្ថុដែលមានភាពត្រឹមត្រូវស្របតាមស្តង់ដារ និងគួរជាតិទុកចិត្តដល់ក្រុមហ៊ុន ធ្វើឱ្យក្រុមហ៊ុននៅតែទទួលបានការគាំទ្រពីសំណាក់អតិថិជន ប៉ុន្តែ យើងសង្ឃឹមថា ក្រយហ៊ុននឹងឆាប់រិះរកដំណោះស្រាយ ដើម្បីកែកំហុសឆ្គងនេះ ឱ្យបានឆាប់រហ័ស ដើម្បីឱ្យក្រុមហ៊ុនមិនមានបញ្ហានាពេលខាងមុខបន្តទៀត។ ជាពិសេស ក្រុមហ៊ុនគួរតែបង្កើតនៅវគ្គបណ្តុះបណ្តាល ដល់គណនេយ្យករទាក់នឹងភាសាបរទេសបន្ថែមទៀត ដើម្បីឱ្យគណនេយ្យករងាយស្រួលក្នុងការអនុវត្តន៍ការងារបានកាន់តែមានប្រសិទ្ធខ្ពស់ផងដែរ។

# មាតិកា

ទំព័រ

អារម្ភកថា ..... i
រចនាសម្ព័ន្ធ ..... ii
សេចក្តីថ្លែងអំណរគុណ ..... iii
អំណះអំណាង ..... vi
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ..... v

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រា ..... 1
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ..... 2
១.តើគណនេយ្យករមានមុខងារ និងតួនាទីអ្វីខ្លះក្នុងក្រុមហ៊ុន Smart ?
២.តើគណនេយ្យករ របស់ក្រុមហ៊ុន Smart មានសារៈសំខាន់អ្វីខ្លះ ?
១.៣ គោលបំណងនៃការស្រាវជ្រាវ ..... 2
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... 3
១.៤.១ ទំហំដែនកំណត់ ..... 3
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ..... 3
១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ..... 3
១.៥.១ ការប្រមូលទិន្នន័យដំបូង ..... 3
១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ..... 3
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ..... 3
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... 4

## ជំពូកទី២
## រំលឹកទ្រឹស្តី

២.១ លក្ខណៈទូទៅនៃរបស់គណនេយ្យករ ..... 5
២.១.១ និយមន័យនៃគណនេយ្យ ..... 5
២.១.២ ប្រវត្តរបស់គណនេយ្យ ..... 6
២.១.៣ មុខងារនិងអត្ថប្រយោជន៍គណនេយ្យ ..... 6
២.១.៤ លក្ខណៈសម្បត្តិរបស់គណនេយ្យ ..... 6
២.២តួនាទីរបស់គណនេយ្យករ ..... 8
២.២.១ និយមន័យនៃគណនេយ្យករ ..... 8

២.២.២ប្រវត្តរបស់គណនេយ្យករ ........ 8
២.២.៣ មុខងារ និងតួនាទីគណនេយ្យករ ........ 9
២.៣ សារៈសំខាន់របស់គណនេយ្យករ ........ 11
២.៣.១ និយមន័យនៃសារៈសំខាន់ ........ 11
២.៣.២ លក្ខណៈសម្បត្តិរបស់គណនេយ្យករ ........ 12

## ជំពូកទី៣

## លទ្ធផលនៃការស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅនៃក្រុមហ៊ុនសេវាកម្ម Smart Axiata ........ 13
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុនសេវាកម្ម Smart Axiata ........ 14
៣.១.២ បេសកកម្ម ទស្សនៈ និងគុណតម្លៃរបស់ក្រុមហ៊ុនផ្គត់ផ្គង់សេវាកម្ម Smart Axiata ........ 14
ក.បេសកកម្ម ........ 14
ខ.ទស្សនៈវិស័យ ........ 15
គ. គុណតម្លៃក្នុងក្រុមហ៊ុន ........ 15
ឃ. ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន Smart Axiata ........ 16
ឃ. របាយការណ៍និរន្តភាពរបស់ក្រុមហ៊ុន Smart Axiata ........ 18
៣.១.៣ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនផ្គត់ផ្គង់សេវាកម្ម Smart Axiata Co., Ltd ........ 20
៣.២ តួនាទីគណនេយ្យករក្នុងក្រុមហ៊ុន Smart ........ 21
៣.២.១ ភារកិច្ចគណនេយ្យករ ........ 21
៣.២.២ ការកត់ត្រាចំណូលចំណាយ ........ 23
៣.២.៣ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ........ 23
៣.២.៤ ការរៀបចំរបាយការណ៍ចំណេញ-ខាតរបស់ក្រុមហ៊ុន ........ 24
៣.២.៥ ការបិទបញ្ជីរបស់ក្រុមហ៊ុន ........ 24
៣.៣ សារៈសំខាន់របស់គណនេយ្យករ ក្នុងក្រុមហ៊ុន Smart ........ 25

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........ 27
៤.២ ការវិភាគលើចំណុចខ្សោយ ........ 28

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........ 29
៥.២ ការផ្តល់អនុសាសន៍ ........ 30

# ជំពូកទី១
# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃរាជរដ្ឋាភិបាលកម្ពុជាយើង បានខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍជាតិ ដូចជាការរៀបចំហេដ្ឋារចនាសម្ព័នក៏ដូចជាផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីពេទ្យ និងអគារតូចធំពាសពេញប្រទេស។ មិនតែប៉ុណ្ណោះ ប្រទេសកម្ពុជាកំពុងនឹងរីកលូតលាស់ជាច្រើនវិស័យ ហើយនិងកំពុងឈានទៅរកភាពរីកចម្រើនជាបន្តបន្ទាប់ ដោយរាជរដ្ឋាភិបាលយើងបាន ខិតខំប្រឹងប្រែង ធ្វើកំណែទម្រង់សេដ្ឋកិច្ចរបស់ខ្លួនឱ្យកាន់តែរីកចម្រើនទាំងវិស័យធនាគារ និងវិស័យសុខាភិបាល។ ការរីកចម្រើនរបស់ប្រទេសកម្ពុជា មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សបែបនេះ ក៏ដោយសារតែមានការចូលរួមពីវិស័យផ្សេងៗដូចជា វិស័យឧស្សាហកម្ម កសិកម្ម វិស័យទេសចរណ៍ វិស័យសំណង់ស៊ីវិល និងពិសេសទៅទៀតនោះ គឺមានសេវាទូរគមនាគមន៍ចល័ត ដែលជាតម្រូវការចាំបាច់របស់ប្រជាជនផងដែរ។

ដោយឡែកនៅប៉ុន្មានឆ្នាំចុងក្រោយនេះ យើងសង្កេតឃើញថាប្រទេសកម្ពុជា មានការរីកចម្រើនខ្លាំងពិសេសផ្នែកទូរគមនាគមន៍ចល័ត ដែលជាផ្នែកមួយនៃការពន្លឿនសេដ្ឋកិច្ចជាតិ ហើយក៏បានចូលរួមចំណែកក្នុងការជម្រុញឱ្យជីវភាពប្រជាពលរដ្ឋខ្មែរមានលក្ខណៈល្អប្រសើរផងដែរ។ ជាក់ស្តែងក៏ដូចជា ក្រុមហ៊ុនសេវាកម្ម Smart Axiata ដែលជាប្រតិបត្តិករទូរគមនាគមន៍ចល័តឈានមុខគេ ក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ន ក្រុមហ៊ុនបាននឹងកំពុងបម្រើអតិថិជនចំនួន ៨លាននាក់ស្ថិតក្រោមស្លាកសញ្ញា«Smart»។ បន្ថែមពីនេះទៅទៀតក្រុមហ៊ុនសេវាកម្ម Smart បានខិតខំពង្រីកសាខារបស់ខ្លួនពាសពេញផ្ទៃប្រទេស មិនថាតាមបណ្តាខេត្ត ឬទីប្រជុំជន។ លើសពីនេះ ទៅទៀតខាងក្រុមហ៊ុន Smart ក៏បានខិតខំបង្កើតនូវ សេវាបច្ចេកវិទ្យាទំនើបទាន់សម័យជំនាន់ទី៤“ 4G LTE ” ក្នុងឆ្នាំ២០១៤ បច្ចេកវិទ្យា 4G LTE Advanced ( ត្រូវបានគេស្គាល់ថា 4G+) ក្នុងឆ្នាំ២០១៦ បច្ចេកវិទ្យា 4G LTE Advanced Pro (ត្រូវបានគេស្គាល់ថា4.5G) ជាមួយ HD Voice (VoLTE) ក្នុងឆ្នាំ២០១៧ ដែលអាចបំពេញនូវសេចក្តីត្រូវការរបស់អតិថិជនរបស់ខ្លួន។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុនសេវាកម្ម Smart Axiata បានរៀបចំការគ្រប់គ្រងរបស់ខ្លួនបានយ៉ាងល្អផងដែរ មិនថាផ្នែកទីផ្សារ រដ្ឋបាល ហិរញ្ញវត្ថុ ឬធនធានមនុស្សនោះឡើយ ដែលជាហេតុនាំមានការគាំទ្រពីសំណាក់អតិថិជនកាន់តែរីកចម្រើនឡើង និងជាកត្តាមួយក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍន៍ទូរគមនាគមន៍។

បើក្រឡេកទៅមើលវិធានការនៃការគ្រប់គ្រងគ្រប់ផ្នែកទាំងអស់សុទ្ធតែមានសារៈសំខាន់ ដែលតម្រូវឱ្យមានការដាក់បទបញ្ញត្តិ ការត្រួតនិនិត្យ ការអនុវត្តតាមផ្នែកនីមួយៗ ឱ្យបានកាន់តែច្បាស់លាស់និងមានប្រសិទ្ធិភាព។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញថាគ្រប់ស្ថាប័នក្រុមហ៊ុនទាំងរដ្ឋ និងឯកជនគឺចាំបាច់ត្រូវតែមាន ឬប្រើប្រាស់នូវប្រព័ន្ធគណនេយ្យ ដើម្បីងាយស្រួលក្នុងការកត់ត្រា រៀបចំរបាយការណ៍ហិរញ្ញវត្ថុ បិទបញ្ជី និងកត់ត្រាចំណូលចំណាយរបស់ក្រុមហ៊ុនឱ្យបានច្បាស់លាស់ នេះសុទ្ធតែជាតួនាទីរបស់គណនេយ្យករ។ ជាពិសេសនោះ គឺគណនេយ្យករជាសរសៃឈាមរបស់ក្រុមហ៊ុន ប្រសិនបើសរសៃឈាមមួយណាដាច់ ឬខូចខាតនោះនឹងអាចបណ្តាលឱ្យមានការរាំងស្ទះ នូវដំណើរការរបស់ក្រុមហ៊ុន និងមានបញ្ហាផ្នែកហិរញ្ញវត្ថុផងដែរ។

ដូច្នេះហើយ បានជាក្រុមហ៊ុនសេវាកម្ម Smart Axiata បានជ្រើសរើសគណនេយ្យករណា ដែលមានជំនាញខ្ពស់ក្នុងការធ្វើប្រតិបត្តិដំណើរការរបស់ក្រុមហ៊ុន។

ហេតុដូចនេះ ទើបក្រុមយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ“**សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុនSmart**” យកមកធ្វើ ការសិក្សាស្រាវជ្រាវ ដើម្បីឱ្យមានការយល់ដឹងកាន់តែច្បាស់ទាក់ទងទៅនឹងតួនាទីរបស់គណនេយ្យករ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីធានាបាននូវប្រសិទ្ធិភាព និងសម្រេចបានតាមគោលដៅគ្រប់ស្ថាប័នទាំងអស់ បានយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើការគ្រប់គ្រងបុគ្គលិករបស់ខ្លួន ដោយបែកចែកការងារឱ្យត្រូវនឹងមុខងារ និងជំនាញរបស់ពួកគេ ដើម្បីឱ្យពួកគេងាយស្រួលក្នុងការអនុវត្តការងារ ដោយមានប្រសិទ្ធិភាពស្របតាមគោលការរបស់ក្រុមហ៊ុន និងបំពេញតម្រូវការរបស់អតិថិជន។ ក្នុងនេះដែរក្រុមហ៊ុនសេវាកម្ម Smart ដែលជាក្រុមហ៊ុនទូរគមនាគមន៍ចល័តបានផ្តោតសំខាន់ទៅលើគណនេយ្យករ ដែលជាផ្នែកមួយ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញឱ្យក្រុមហ៊ុនមានភាពរីកចម្រើន។ ដូចនេះបានជាក្រុមយើងខ្ញុំ មានសំណួរពីរដើម្បីចោទសួរទៅប្រធានបទខាងលើ៖

១.តើគណនេយ្យករមានតួនាទីអ្វីខ្លះក្នុងក្រុមហ៊ុន Smart?

២.តើគណនេយ្យករ របស់ក្រុមហ៊ុន Smart មានសារៈសំខាន់អ្វីខ្លះ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺស្ថិតក្នុងគោលបំណងរួមចំណែក ដើម្បីឱ្យមានភាពប្រសើរឡើងក្នុងការយល់ដឹងអំពីតួនាទីរបស់គណនេយ្យករឱ្យកាន់តែទូលំទូលាយ។ យើងបានដឹងរួចមកហើយថា គ្រប់ស្ថាប័នទាំងរដ្ឋ និងឯកជនគឺចាំបាច់ត្រូវតែមានគណនេយ្យករជំនាយជាច្រើនរូបដើម្បីធ្វើការ គ្រប់គ្រងចំណូលចំណាយរបស់ក្រុមហ៊ុនដើម្បីឱ្យមានភាពជាក់លាក់ ច្បាស់លាស់ និងសុក្រិត។ ជាពិសេសសិក្សាពីភាពសារៈសំខាន់ និងផលប្រយោជន៍របស់គណនេយ្យករឱ្យកាន់តែមានភាពកម្ពិតថែមទៀតផង។ គោលបំណងចម្បងគឺសិក្សាអំពីដំណើរការនិងស្ថានភាពទូទៅរបស់ក្រុមហ៊ុនដែលផ្តោតសំខាន់ទៅលើតួនាទីគណនេយ្យករ ដែលរួមមាន៖

- ស្ថានភាពទូទៅរបស់ក្រុមហ៊ុនSmart Axiata ផ្ទាល់
- សេវាកម្មផ្សេងៗដែលក្រុមហ៊ុនមានបម្រើដល់អតិថិជន
- រចនាសម្ព័ន្ធចាត់តាំងរបស់ក្រុមហ៊ុន Smart
- សិក្សាពីការគ្រប់គ្រងប្រតិបត្តិការក្នុងក្រុមហ៊ុន Smart
- ស្វែងយល់ពីរបៀបនៃការកត់ត្រាចំណូល ចំណាយក៏ដូចជាការបិទបញ្ជីរបស់ក្រុមហ៊ុន
- តួនាទីរបស់គណនេយ្យករនៅក្នុងក្រុមហ៊ុន Smart
- ផលប្រយោជន៍នៃគណនេយ្យករក្នុងក្រុមហ៊ុន Smart

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ក្នុងការសិក្សាស្រាវនេះ គឺស្រាវជ្រាវក្នុងឆ្នាំ២០២៣ ដែលយើងត្រូវការព័ត៌មានច្រើនជាពិសេសព័ត៌មានដែលតម្រូវឱ្យមានការចុះសាកសួរដល់ក្រុមហ៊ុនដោយផ្ទាល់តែម្តង។ ហើយក្រុមរបស់ខ្ញុំបាទក៏បានសិក្សាស្រាវជ្រាវបន្ថែមចេញពីប្រព័ន្ធអីនធឺណេត ការចូលទៅមើលនៅក្នុងpageផ្លូវការរបស់Smart Axiata និងការចុះទៅសាខារបស់ក្រុមហ៊ុន Smart ផ្ទាល់នៅសង្កាត់ទទួលទំពូង ផងដែរ ដើម្បីស្វែងយល់កាន់តែច្បាស់ជាក់លាក់ពិតប្រាកដមួយក្នុងការរៀបរៀងចងក្រងជាឯកសារនេះឡើង។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ដោយការសិក្សាស្រាវជ្រាវទៅលើ សារៈសំខាន់របស់គណនេយ្យករ មានន័យទូលំទូលាយដូច្នេះក្រុមរបស់យើងខ្ញុំ ធ្វើការកណត់យកការស្រាវជ្រាវផ្តោតទៅលើតែប្រធានបទ “**សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុនសេវាកម្ម Smart Axiata**” ក្នុងឆ្នាំ2023ដែលមានសាខានៅ សង្កាត់ទទួលទំពូងរាជធានីភ្នំពេញ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

ទិន្នន័យចម្បងដែលមាននៅក្នុងការស្រាវជ្រាវនេះ ត្រូវបានដកស្រង់ចេញពី៖

-ការចុះសាកសួរព័ត៌មានដោយផ្ទាល់

-គេហទំព័រ និង Pageរបស់ក្រុមហ៊ុន Smart Axiata

-ឯកសារក្នុងបណ្ណាល័យនៃវិទ្យាស្ថានវ៉ាន់ដា

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

ទិន្ន័យបន្ទាប់បន្សំ ដែលមាននៅក្នុងការស្រាវជ្រាវនេះត្រូវបានប្រមូលតាមរយៈឯកសារដែលទាក់ទងទៅនឹងប្រធានបទដូចជា សៀវភៅពុម្ព មូលដ្ឋានគ្រឹះគណនេយ្យ សៀវភៅនិងគេហទំព័រផ្សេងទៀតដែលពាក់ព័ន្ធនឹងផ្នែកគណនេយ្យ និងការផ្តល់មតិកែលម្អរបស់លោកគ្រូអ្នកគ្រូ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ភាពវិជ្ជមានរបស់គណនេយ្យករដែលត្រូវលម្អិតទៅលើកត្តាជាច្រើន ហើយវាជាផ្នែកមួយយ៉ាងសំខាន់ក្នុងការកត់ត្រាចំណូល ចំណាយរួមទាំងការបិទបញ្ជីរបស់ក្រុមហ៊ុន Smart ផងដែរ តែក្នុងប្រធានបទនេះផ្តោតសំខាន់ទៅលើ សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុនសេវាកម្ម Smart Axiata ។

សារៈសំខាន់នៃការស្រាវជ្រាវនេះ គឺដើម្បីស្វែងយល់បន្ថែមនៃដំណើរការរបស់ក្រុមហ៊ុន និងតួនាទីយ៉ាងសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុន Smart ឱ្យកាន់តែច្បាស់លាស់ថែមទៀត។ មិនតែប៉ុណ្ណោះការសិក្សាស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយបង្កើនភាពច្បាស់លាស់ដល់ការកត់ត្រាចំណូល ចំណាយ ក៏ដូចជាបានដឹងអំពី សារៈប្រយោជន៍របស់គណនេយ្យករ និងទទួលបានបទពិសោធន៍ការងារបន្ថែមផងដែរ។ ចំណេកការស្រាវជ្រាវនេះផ្ទាល់ និង ចងក្រងទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយយកទៅសិក្សា និងស្រាវជ្រាវបន្ថែម។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**ជំពូកទី១ ៖ សេចក្តីផ្តើម** ជំពូកនេះបង្ហាញអំពី លំនាំបញ្ហារនៃការស្រាវជ្រាវ ចំណោទបញ្ហារនៃការស្រាវជ្រាវ គោល បំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ។

**ជំពូកទី២៖ រំលឹកទ្រឹស្តី** ជំពូកនេះបកស្រាយអំពីលក្ខណៈទូទៅរបស់គណនេយ្យករដូចជា និយមន័យ ប្រវត្តរបស់គណនេយ្យករ និងទ្រឹស្តីគណនេយ្យករនៅក្នុងក្រុមហ៊ុន Smart Axiata ។

**ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវ** គឺបង្ហាញអំពីស្ថានភាពទូទៅរបស់ក្រុមហ៊ុនសេវាកម្ម Smart Axiata (ប្រវត្តរបស់ក្រុមហ៊ុន ចក្ខុវិស័យ បេសកកម្ម និងទស្សនៈវិស័យ) រចនាសម្ព័នរបស់ក្រុមហ៊ុនសេវាកម្ម Smart Axiata និងតួនាទីរបស់គណនេយ្យករក្នុងក្រុមហ៊ុនក៏ដូចជាមុខងារផ្សេងៗទៀតរបស់គណនេយ្យករ។

**ជំពូកទី៤ ៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** ជំពូកនេះនិយាយអំពីចំណុចដែលមានន័យត្រឹមត្រូវពេញលេញ និងចំណុចដែលមានន័យខ្វះខាតខ្លះៗដើម្បីយកទៅកែលំអឱ្យមានភាពត្រឹមត្រូវនឹងមានន័យពេញលេញ និងត្រឹមត្រូវទៅតាមសំណោរឡើងវិញ។

**ជំពូកទី៥ ៖ សេក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** គឺជាការសន្និដ្ឋានសរុបទៅលើស្ថានភាពជាក់ស្តែងទៅលើសារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុន Smart Axiata។ ខ្លឹមសារទាំងមូលនៃការសិក្សាស្រាវជ្រាវ ជាផ្នែកមួយដែលផ្តល់នូវគោលគំនិតមួយចំនួនដែលមានការខ្វះខាត ដើម្បីជួយបំពេញបន្ថែមឱ្យមានលក្ខណៈល្អប្រសើរឡើងវិញ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# សារៈសំខាន់របស់គណនេយ្យករ

## ២.១ លក្ខណៈទូទៅរបស់គណនេយ្យករ

### ២.១.១ និយមន័យនៃគណនេយ្យ

- ពាក្យថាគណនេយ្យ គឺជាដំណើរការនៃការវិភាគកត់ត្រាសង្ខេបបកស្រាយ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ជាទ្រព្យសកម្ម បំណុល ដើមទុន ចំណូល និងចំណាយរបស់អង្គភាព ឬអាជីវកកម្មដែលអ្នកប្រើប្រាស់ដូចជាក្រុមហ៊ុនអ្នកវិនិយោគជាដើម។
- គណនេយ្យ គឺជាមុខវិជ្ជាបែបវិទ្យាសាស្ត្រដែលសិក្សាលម្អិតអំពីរបៀបកត្រាការរកស៊ី ឬប្រតិបត្តិការសេដ្ឋកិច្ចក្នុងគោលបំណងសរុបតួលេខ នៃបណ្តាគណនេយ្យទាំងប្រាំក្រុមទៅជំឡើង Income Statements និង Balance Sheet[1]។
- គណនេយ្យ គឺជាសិល្បៈនៃការកត់ត្រា ជាដំណើរការប្រមូលព័ត៌មានហិរញ្ញវត្ថុ និងទិន្ន័យផ្សេងៗទៀត ដែលទាក់ទងទៅនឹងអង្គភាពអាជីវកម្មមួយ ដើម្បីធ្វើការកត់ត្រាវាស់វែងចាត់ថ្នាក់ ក្នុងគោលបំណងធ្វើការបោះផ្សាយនូវរបាយការណ៍ហិរញ្ញវត្ថុនៅចុងការិយនីមួយ[2]។
- តាមរយៈ American Institute of Certified Accountant (AICPA) បានឱ្យនិយមន័យពាក្យគណនេយ្យថា គឺជាសកម្មភាពផ្តល់សេវាកម្មមួយ ដែលមានមុខងារផ្តល់នូវព័ត៌មានជាបរិមាណ ស្តីអំពីព័ត៌មានសេដ្ឋកិច្ចរបស់អាជីវកម្មដែលជាគោលបំណងចម្បងនៃព័ត៌មានហិរញ្ញវត្ថុទាំងនោះ គឺជាព័ត៌មានដែលមានលក្ខណៈជាការជឿទុកចិត្តក្នុងការយកទៅប្រើប្រាស់តាមតម្រូវការដើម្បីជាការវិភាគ និងសម្រេចចិត្តស្តីពីស្ថានភាពហិរញ្ញវត្ថុសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។
- គណនេយ្យ គឺជាភាសាអាជីវកម្មមួយ ត្រូវបានគេប្រើប្រាស់ក្នុងការគ្រប់គ្រងទិន្នន័យ ផ្នែកហិរញ្ញវត្ថុរបស់អង្គភាពអាជីវកម្ម[3]។
- គណនេយ្យ គឺជាដំណើរនៃសកម្មភាពអាជីវកម្មសំខាន់ៗ បីដែលរួមមានការកំណត់អត្តសញ្ញាណសកម្មភាពអាជីវកម្ម ( Identifying Business Activities ) ការកត់ត្រាអាជីវកម្ម ( Recording Business Actives ) នឹងផ្តល់ព័ត៌មានអំពីសកម្មភាពអាជីវកម្ម( Communicating Business Active ) ដែលទាក់ទងអាចជឿទុកចិត្តបានដើម្បីជួយអ្នកប្រើប្រាស់បង្កើតការសម្រេចចិត្តក្នុងការចាត់ចែងអាជីវកម្ម។

ដូចនេះ ពាក្យថាគណនេយ្យដែលមានន័យរួមថា គឺជាការប្រមូលផ្តុំការវាស់វែងការកត់ត្រាព័ត៌មានរបាយការណ៍ រួចបោះផ្សាយនូវរបាយការណ៍ខ្លួនយោងទៅតាមការិយបរិច្ឆេទនីមួយៗផងដែរ។

---

[1] ដកស្រង់ចេញពីសៀវភៅមូលដ្ឋានគ្រឹះគណនេយ្យហិរញ្ញវត្ថុ របស់វិទ្យាស្ថានវ៉ាន់ដា

[2] ដកស្រង់ចេញពី(ស៊ឹមវិចិត្រet,2009 )

[3] តាមសៀវភៅរបស់លោក Rabert Fmery,1998

**២.១.២ ប្រវត្តិគណនេយ្យ**

នៅក្នុងឆ្នាំ១០៦៦ ក្នុងជំនាន់ព្រះអង្គម្ចាស់ក្សត្រី Elizabeth M មានមេទ័ពមួយឈ្មោះថា William គឺជាអ្នកចម្បាំងមួយដ៏ពូកែហើយបានប្រមូលកុលសម្ព័ន្ធពួក Argo-Saxon បង្កើតជាចក្រភពអង់គ្លេស។ បន្ទាប់ពីវាយឈ្នះលើកុលសម្ព័ន្ធនោះ រួចហើយមេទ័ពនោះ ត្រូវបានព្រះអង្គម្ចាស់ក្សត្រីឱ្យដើររុករានទន្ទ្រាន ដើម្បីរាប់មើល និងវាយតម្លៃដូចជាដី ធនធានធម្មជាតិ មនុស្ស និងសត្វពាហណៈទាំងអស់ទោះជារបស់រដ្ឋក្តី ឬ ជារបស់ប្រជាពលរដ្ឋក្តី។ បន្ទាប់មក William ក៏ចាប់ផ្តើមគណនាពីបំណុលទាំងបំណុលក្នុងប្រទេស និងជាមួយបរទេសទៀត។ ពេលនោះ William រកឃើញពីភាពខុសគ្នារវាងទ្រព្យសម្បត្តិរបស់ព្រះអង្គម្ចាស់ក្សត្រីរបស់ជនជាតិអង់គ្លេស និងបំណុលរបស់ព្រះអង្គដែលជំពាក់គេវិញ។ ភាពខុសគ្នានេះគេឱ្យឈ្មោះថា ទ្រព្យសម្បត្តិពិតរបស់ព្រះអង្គម្ចាស់ក្សត្រីយ៍។

**Assets = Liabilities + Owner's Equity**

**ទ្រព្យសកម្ម = បំណុល + ទុនរបស់ក្រុមហ៊ុន**

ពេល William ចេញធ្វើប្រតិបត្តិការដើររុករានទន្ទ្រានក្នុងទឹកដី Anglo-Saxon ទាំងមូលធ្វើឱ្យប្រជាពលរដ្ឋមានការភ័យព្រួយយ៉ាងខ្លាំង។ កិច្ចការលើកនេះគឺ William បានធ្វើទាល់តែសម្រេចរួចក៏ចងក្រងយុគសម័យថ្មីនៃឧស្សាហកម្ម (Industrial age) នៅក្នុងសតវត្សទី១៩ និងបន្ទាប់មកមានការកកើតឡើង របស់សាជីវកម្មធំៗ ព្រមទាំងការកកើតឡើងនៃការបែងចែកតួនាទីរវាងម្ចាស់ក្រុមហ៊ុន និងអ្នកគ្រប់គ្រងមុខជំនួញដែលនោះធ្វើឱ្យការគ្រប់គ្រងគណនេយ្យក្នុងការធ្វើអាជីវកម្មកាន់តែមានសារៈសំខាន់ថែមទៀត។ លើសពីនេះទៅទៀតប្រតិបត្តិការនៅក្នុងអាជីវកម្មមានភាពស្មុគស្មាញខ្លាំងដែលចាំបាច់ត្រូវមានគណនេយ្យ ដើម្បីមកធ្វើការកែសម្រួល និងតាមដានរាល់ចំណូលចំណាយដែលកើតមានឡើងនៅក្នុងអង្គភាព[4]។

**២.១.៣ មុខងារនិងអត្ថប្រយោជន៍គណនេយ្យ**

យើងដឹងហើយថា គណនេយ្យគឺជាដំណើរការនៃការវាស់វែងរាល់គ្រប់ បណ្តាលក្រុមគណនីធំៗទាំងប្រាំក្រុម និងការទំនាក់ទំនងដែលបានបង្ហាញនូវរាល់ព័ត៌មានសេដ្ឋកិច្ច ហើយយកទៅប្រើប្រាស់ដើម្បីរាយការណ៍សកម្មភាពហិរញ្ញវត្ថុរបស់អង្គភាពស្វែងរកប្រាក់ចំណេញ ក៏ដូចជាអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

**២.១.៤ លក្ខណៈសម្បត្តិរបស់គណនេយ្យ**

**ក.មានផ្លូវអាជីពច្បាស់លាស់**

ប្រសិនបើ អ្នកកំពុងសិក្សាគណនេយ្យអ្នកកំពុងរៀនជំនាញជាក់ស្តែងអំពីលេខកូដ និងការវិភាគតម្លៃដែលនិយោជកត្រូវការ។ នេះផ្តល់ឱ្យអ្នកនូវផ្លូវអាជីពច្បាស់លាស់ បើប្រៀបធៀបទៅនឹងអ្នកដែលជ្រើសរើសសិក្សាភាសាអង់គ្លេស ឬទស្សនៈវិជ្ជាដែលលទ្ធផលនៃអាជីពដែលមានសក្តានុពលពិបាកកំណត់។ ប្រសិនបើអ្នកជ្រើសយកសញ្ញាបត្រគណនេយ្យ អ្នកនឹងមានគំនិតដ៏រឹងមាំនៃកន្លែងដែលអាជីពរបស់អ្នកនឹងនាំអ្នក[5]។

[4] ដកស្រង់ចេញពីសៀវភៅមូលដ្ឋានគ្រឹះគណនេយ្យហិរញ្ញវត្ថុ របស់វិទ្យាស្ថានវ៉ាន់ដា

[5] ដកស្រង់ចេញពីសៀវភៅមូលដ្ឋានគ្រឹះគណនេយ្យហិរញ្ញវត្ថុ របស់វិទ្យាស្ថានវ៉ាន់ដា

**ខ. ជាកន្លែងការងារដែលមានស្ថេរភាព និងរីកចម្រើន**

គណនេយ្យ មិនមែនជាវិជ្ជាជីវៈដែលនឹងបាត់ទៅវិញ ឬត្រូវបានគេយកចេញងាយៗទេ។ ទស្សនៈវិស័យការងារនៅ ក្នុងគណនេយ្យត្រូវបានគេព្យាករណ៍ថា នឹងកើនឡើងក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ ដរាបណាមនុស្សត្រូវការជំនួយពន្ធ និងអាជីវកម្ម វានឹងមានតម្រូវការសម្រាប់គណនេយ្យករ។ ការិយាល័យស្ថិតិការងារ (BLS)ព្យាករណ៍ថា ការងារក្នុងវិស័យគណនេយ្យនឹងកើនឡើង១១% ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២៤។ នេះលឿនជាងអត្រាមធ្យម7ភាគរយរបស់ជាតិ។ កត្តាធំមួយដែលជំរុញឱ្យមានកំណើននេះ គឺថាជំនាន់ Baby Boomer និងបន្តការចាកចេញពីកម្លាំងពល កម្មក្នុងពេលប៉ុន្មានឆ្នាំខាងមុខនេះ ដែលគួរតែត្រួសត្រាយផ្លូវសម្រាប់ឱកាសសម្រាប់គណនេយ្យករថ្មី។

**គ. អ្នកនឹងមានសក្តានុពលសម្រាប់ការរីកចម្រើនជំនាញវិជ្ជាជីវៈ**

បន្ទាប់ពីបញ្ចប់ការសិក្សា អ្នកអាចចាប់ផ្តើមជាអ្នកចូលនិវត្តន៍កម្រិតមួយ ប៉ុន្តែសក្តានុពលសម្រាប់ការរីកចម្រើនអាចមានភាពល្អប្រសើរ។ និស្សិតបញ្ចប់ការសិក្សាផ្នែកគណនេយ្យជាច្រើន នឹងផ្តើមជាគណនេយ្យករបុគ្គលិកសវនករក្មេងខ្ចី នៅក្នុងគណនេយ្យសាធារណៈ ឬជំនួយការនៅក្នុងការិយាល័យរបស់អ្នកត្រួតពិនិត្យក្នុងគណនេយ្យឯកជន នៅពេលពួកគេចាប់ផ្តើមរៀបចំផ្លូវអាជីពរបស់ពួកគេ។ បន្ទាប់ពីទទួលបានការបង្កើត និងទទួលបានបទពិសោធន៍ការរីកចម្រើនខាងអាជីវកម្មអាចសម្រេចបានតាមរយៈការបំពេញការងារ នៅលើការងារ និងការអប់រំបន្ថែម ឬការផ្តល់វិញ្ញាបនប័ត្រដូចជាការទទួលបានអនុបណ្ឌិតឬ CPA ។

**ឃ. សក្តានុពលនៃការរកលុយគឺមានលក្ខណៈអំណោយផល**

អ្នកចង់រកប្រាក់ខែយ៉ាងសប្បុរស ដើម្បីឱ្យអ្នកអាចចំណាយលើការចំណាយ និងរស់នៅបានស្រួលមែនទេ? អាជីពគណនេយ្យមានសក្តានុពលក្នុងការធ្វើឱ្យអ្នកមានរបៀបរស់នៅបែបនោះ។ ជាការពិតណាស់ BLS បានរាយការណ៍ថា ១០%នៃអ្នករកប្រាក់ចំណូលមានចំនួន120.000 ដុល្លារ មិនមែនជារឿងអាក្រក់ទេ បើប្រៀបធៀបទៅនឹងប្រាក់ខែមធ្យមរបស់ជាតិ ដែលមានចំនួន37.040ដុល្លារ។ លើសពីនេះ គណនេយ្យករពេញម៉ោងជាច្រើនទទួលបានអត្ថប្រយោជន៍ជាច្រើន ដូចជាការថែទាំសុខភាពពេលវេលាវិស្សមកាលផែនការចូលនិវត្តន៍ និងច្រើនទៀត។

**ង. អ្នកអាចធ្វើការនៅទីណាដែលអ្នកចង់ធ្វើ**

ជាមួយវិស័យអាជីពមួយចំនួន អ្នកប្រហែលជាត្រូវដកហូតជីវិតរបស់អ្នក ហើយផ្លាស់ទៅមជ្ឈមណ្ឌលឧស្សាហកម្មដើម្បីរកការងារធ្វើ។ ទោះជាយ៉ាងណា គណនេយ្យមាននិន្នាការជាតម្រូវការសកល។ ចាប់ពីកសិកររហូតដល់ក្រុមហ៊ុនអភិវឌ្ឍន៍ សូហ្វវែរ អ្នកគ្រប់គ្នាអាចប្រើសេវាកម្មគណនេយ្យករ។ នេះផ្តល់ឱ្យគណនេយ្យករ នូវចំនួនទឹកប្រាក់សមរម្យនៃភាពបត់បែននៅពេល ដែលជ្រើសរើសយកកន្លែងដែលពួកគេចង់ដោះស្រាយ។

**ច. មានសក្តានុពលសហគ្រិន**

ក្តីសុបិន្តនៃការក្លាយ ជាចៅហ្វាយផ្ទាល់របស់អ្នកគឺនៅរស់រានមានជីវិត និងល្អនៅក្នុងវិជ្ជាជីវៈគណនេយ្យ។ ប្រសិនបើ អ្នកចង់ធ្វើដោយខ្លួនឯងការចាប់ផ្តើមក្រុមហ៊ុនគណនេយ្យមួយ គឺនៅជិតនឹងអ្នក។

## ២.២ តួនាទីរបស់គណនេយ្យករ

### ២.២.១ និយមន័យនៃគណនេយ្យករ

គណនេយ្យករ គឺជាដំណើរនៃការកំណត់អត្តសញ្ញាណកម្មការវាស់វែង និងការកត់ត្រាការពិពណ៌នា និងការបកស្រាយនូវប្រតិបត្តការសេដ្ឋកិច្ចរបស់អង្គភាព និងអាជីវកម្មមួយនៅក្នុងកំឡុងពេលវេលាមួយដ៏ជាក់លាក់។ម៉្យាងទៀតរាល់ព័ត៌មានគណនេយ្យករទាំងអស់ ត្រូវពិពណ៌នាអំពីសាច់ប្រាក់។

គណនេយ្យករ គឺជាអ្នកកត់ត្រានិងថែរក្សា ប្រតិបត្តិការហិរញ្ញវត្ថុរបស់អង្គភាពសេដ្ឋកិច្ចមួយដែលមានទម្រង់សរសេរជាលាយលក្ខណ៍អក្សរ។អង្គភាពសេដ្ឋកិច្ចមិនមានសំដៅលើសហគ្រាសស្វែងរកប្រាក់ចំណេញប៉ុណ្ណោះទេថែមទាំងសំដៅលើអង្គភាពមិនស្វែងរកប្រាក់ចំណេញផងដែរ[6]។

តាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជំពូក១ មាត្រា២បានចែងថា ពាក្យគណនេយ្យក្នុងច្បាប់នេះ គឺជាប្រព័ន្ធមួយដែលប្រើដើម្បីកំណត់កត់ត្រាផ្ដុំបញ្ចូលគ្នាវាស់វែងចាត់ថ្នាក់ និងបង្ហាញនូវព័ត៌មានហិរញ្ញវត្ថុដែរទាក់ទងនិងសកម្មភាពនៃអង្គភាពមួយ។

គណនេយ្យករ ជាអ្នកដែលកាន់ការងារពាក់ព័ន្ធនឹងគណនេយ្យ ដែលផ្ដោតទៅលើរឿងដែលបានកើតឡើងរួចទៅហើយគិត និងវិភាគដោយប្រុងប្រយ័ត្នមុនរៀបចំជារបាយការណ៍ហិរញ្ញវត្ថុដូចជា តារាងតុល្យភាព , របាយការណ៍ចំណេញឬខាត និង របាយការណ៍លំហូរសាច់ប្រាក់ជាដើម មុននឹងដាក់ទៅឱ្យផ្នែកផ្សេងទៀតក្នុងក្រុមហ៊ុន ឬ អង្គភាពយកទៅប្រើប្រាស់តាមតម្រូវការ។ អាជីពជាគណនេយ្យករមានភាពទូលាយពីលំដាប់អ្នកកត់ត្រាប្រតិបត្តិការតូចមួយក្នុងក្រុមហ៊ុនទៅជា អ្នកជំនាញគណនេយ្យករសាធារណៈ អ្នកជំនាញផ្ដល់សេវាកម្មពន្ធដារ និង សវនករជាដើម។

### ២.២.២ ប្រវត្តរបស់គណនេយ្យករ

គណនេយ្យ មានអាយុកាលរាប់ពាន់ឆ្នាំមកហើយ ដែលមានអាយុកាលតាំងពីសម័យបុរាណ ដូចជាមេសូប៉ូតាមៀ អេហ្ស៊ីប និងរ៉ូម។ នៅក្នុងសង្គមសម័យដើមទាំងនេះ គណនេយ្យករបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុការគ្រប់គ្រងទ្រព្យសម្បត្តិ និងជានាភាពត្រឹមត្រូវនៃកំណត់ត្រាហិរញ្ញវត្ថុ។

គណនេយ្យករម្នាក់ក្នុងចំណោមគណនេយ្យករដែលគេស្គាល់ដំបូងបំផុត គឺ **Luca Pacioli** ដែលជាគណិតវិទូជនជាតិអ៊ីតាលី និងជាអ្នកជំនាញ ***Franciscan*** ដែលជារឿយៗត្រូវបានគេហៅថាជា "បិតានៃគណនេយ្យ" ។ នៅឆ្នាំ **1494 Pacioli** បានបោះពុម្ពសៀវភៅមួយដែលមានចំណងជើងថា "***Summa De Arithmetica, Geometria, Proportioni et Proportionalita***" ដែលរួមបញ្ចូលផ្នែកមួយស្ដីពីគណនេយ្យទ្វេ។ វិធីសាស្ត្រនៃគណនេយ្យនេះ ដែលពាក់ព័ន្ធនឹងការកត់ត្រាប្រតិបត្តិការនីមួយៗនៅក្នុងគណនីពីរដាច់ដោយឡែកពីគ្នា នៅតែត្រូវបានប្រើប្រាស់ដោយគណនេយ្យករជុំវិញពិភពលោកនាពេលបច្ចុប្បន្ននេះ។ ក្នុងអំឡុងបដិវត្តន៍ឧស្សាហកម្មនៅសតវត្សទី ***19*** តួនាទីរបស់គណនេយ្យករបានពង្រីកនៅពេលដែលអាជីវកម្មមានការកើនឡើងក្នុងទំហំ និងភាពស្មុគស្មាញ។ គណនេយ្យករ បានក្លាយជាអ្នកទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ វិភាគទិន្នន័យហិរញ្ញវត្ថុ និងផ្ដល់ដំបូន្មានហិរញ្ញវត្ថុដល់ម្ចាស់អាជីវកម្ម។

[6] ដកស្រង់ចេញពី Page សកលវិទ្យាល័យ បៀលប្រាយ (Accounting Principle)

នៅសតវត្សរ៍ទី 20 វិជ្ជាជីវៈគណនេយ្យបានក្លាយជាផ្លូវការជាមួយនឹងការបង្កើតអង្គការគណនេយ្យវិជ្ជាជីវៈដូចជាវិទ្យាស្ថាន អាមេរិក នៃគណនេយ្យករសាធារណៈដែលមានការបញ្ជាក់ (AICPA) និងវិទ្យាស្ថានគណនេយ្យករ Chartered នៅប្រទេសអង់គ្លេសនិងវែល (ICAEW) ។ អង្គការទាំងនេះ កំណត់ស្តង់ដារសម្រាប់វិជ្ជាជីវៈគណនេយ្យ និងកម្មវិធីវិញ្ញាបនប័ត្រដែលបានបង្កើតឡើងសម្រាប់គណនេយ្យករ។

សព្វថ្ងៃនេះ គណនេយ្យករដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចពិភពលោក ដោយផ្តល់ព័ត៌មានហិរញ្ញវត្ថុ និងដំបូន្មានដល់អាជីវកម្ម រដ្ឋាភិបាល និងបុគ្គល។ ពួកគេមានទំនួលខុសត្រូវ ក្នុងការធានានូវភាពត្រឹមត្រូវ និងសុចរិតភាពនៃកំណត់ត្រាហិរញ្ញវត្ថុ ការអនុលោមតាមបទប្បញ្ញត្តិហិរញ្ញវត្ថុ និងជួយអង្គការធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុដែលមានព័ត៌មាន។ វិជ្ជាជីវៈគណនេយ្យបន្តវិវឌ្ឍន៍ជាមួយនឹងភាពជឿនលឿននៃបច្ចេកវិទ្យា សកលភាវូបនីយកម្ម និងការផ្លាស់ប្តូរស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ[7]។

**២.២.៣ មុខងារ និងតួនាទីគណនេយ្យករ**

**ក.មុខងារ**

អង្កេតនូវរាល់សកម្មភាព ឬព្រឹត្តិការណ៍សេដ្ឋកិច្ចដែលកើតឡើង ហើយត្រូវបង្ហាញអត្តសញ្ញាណ និងការវាស់វែងក្នុងលក្ខណ៍ហិរញ្ញវត្ថុនូវព្រឹត្តិការណ៍សេដ្ឋកិច្ចផ្សេងៗដើម្បីពិចារណាទៅលើសកម្មភាពទាំងនោះ ។

- បន្ទាប់មកត្រូវកត់ត្រា និងចាត់ថ្នាក់ជាក្រុមៗឱ្យបានច្បាស់លាស់រួច ធ្វើសេចក្តីសង្ខេបនូវព្រឹត្តិការណ៍ទាំងនោះ ។
- រាយការណ៍នូវព្រឹត្តិការណ៍សេដ្ឋកិច្ច ដោយរៀបចំឯកសារដល់អ្នកគ្រប់គ្រងរបស់ខ្លួនដល់អ្នកវិនិយោគម្ចាស់បំណុល និងអ្នកប្រើប្រាស់របាយការណ៍ទាំងនេះ ដើម្បីអោយពួកគេវាយតម្លៃប្រៀបធៀបទៅលើប្រតិបត្តិការសេដ្ឋកិច្ចទាំងនេះ ជាមួយដៃគូរប្រកួតប្រជែង និងហេតុការណ៍ដែលកើតឡើងពីឆ្នាំមុន ដើម្បីព្យាករណ៍នាពេលខាងមុខនិងធ្វើសេចក្តីសម្រេចចិត្ត ។
- តាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជំពូក៦មាត្រា១៧ បានចែងថា វិជ្ជាជីវៈគណនេយ្យការបំពេញវិជ្ជាជីវៈជាគណនេយ្យករជំនាញ ត្រូវសម្រេចដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានចុះឈ្មោះក្នុងបញ្ជីប្រតិស្រុតដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់នោះការបំពេញវិជ្ជាជីវៈ ជាគណនេយ្យករ ជំនាញមានសមត្ថភាពជាមួយមុខងារសាធារណៈ និងមុខងារនយោបាយក្នុងអង្គការនីតិបញ្ញត្តិ នីតិប្រតិបត្ត និងតុលាការ ។

**ខ.តួនាទី**

- កត់ត្រាប្រតិបត្តិការដែលកើតឡើងប្រចាំរបស់ក្រុមហ៊ុន
- គ្រប់គ្រងចំណូល-ចំណាយរបស់ក្រុមហ៊ុន
- គ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន
- ធ្វើផែនការ និងរៀបចំថវិការ (Planning and Budget)
- ធ្វើរបាយការណ៍ប្រកាសពន្ធ និងរៀបចំបញ្ជីចំណាយលើប្រាក់ខែបុគ្គលិក

[7] ដកស្រង់ និងបកប្រែចេញពីសៀវភៅ Summa de arithmetica របស់លោក Pacioli ជនជាតិ អ៊ីតាលី

- រៀបចំតំឡើងរបាយការណ៍ហិរញ្ញវត្ថុសំខាន់ៗដូចជា៖
  - ☞ របាយការណ៍តុល្យការ (Balance Sheet) តារាងតុល្យការ (Balance Sheet) គឺជារបាយការណ៍ហិរញ្ញវត្ថុមួយប្រភេទ ដែលបង្ហាញពីប្រភពមូលនិធិ និងការប្រើប្រាស់មូលនិធិរបស់ក្រុមហ៊ុន នៅក្នុងពេលជាក់លាក់មួយ។ វាបង្ហាញពីស្ថានភាពរបស់ទ្រព្យអសកម្ម ឬបំណុលដើមទុនរបស់ម្ចាស់កម្មសិទ្ធិ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន។

**សមីការគណនេយ្យគឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធគណនេយ្យ៖**

ទ្រព្យសកម្ម = បំណុលទ្រព្យអកម្ម + មូលធនរបស់ម្ចាស់កម្មសិទ្ធិ

Assets = Liabilities + Owner’s Equity

  - ☞ របាយការណ៍លទ្ធផល (Income Statements) : គឺជារបាយការណ៍មួយដែលបង្ហាញឱ្យយើងឃើញពីសកម្មភាព ដែលយើងប្រតិបត្តិនៅក្នុងកំឡុងពេលថា ក្រុមហ៊ុនចំណេញ ឬខាត។ ហើយគេរៀបចំវាឡើង នៅចុងការិយបរិច្ឆេទដោយពាក់ព័ន្ធទៅនឹងគណនេយ្យពីរ គឺគណនីចំណូល (Revenue) និងគណនីចំណាយ (Expense) មានទម្រង់ដូចខាងក្រោម៖
    - ត្រូវដាក់ឈ្មោះក្រុមហ៊ុនដែលត្រូវរៀបចំរបាយការណ៍
    - ដាក់ឈ្មោះរបាយការណ៍ដែលយើងត្រូវរៀបចំ
    - ដាក់កំពេលយើងយើងធ្វើវា
    - ដាក់គណនីចំណូលលើគណនីចំណាយ និងយកចំណូលដកចំណាយ នោះលទ្ធផលអាចចេញជាចំណេញ ឬខាត។
  - ☞ របាយការណ៍លំហូរសាច់ប្រាក់ (Statements of Cash Flow) : គឺជារបាយការណ៍បង្ហាញអំពីការព្យាករឬការត្រួតពិនិត្យជាក់ស្តែងទៅលើប្រាក់ហូរចូលនិងហូរចេញ។ ការប្រមូលប្រាក់បានពីការលក់ដូរទំនិញ ឬប្រាក់បានមកពីការធ្វើអាជីវកម្ម ក៏ដូចជាប្រាក់ខែ ឬប្រាក់បានមកពីការជួលអចលនទ្រព្យជាដើម គេហៅថាលំហូរសាច់ប្រាក់ចូល។ ហើយប្រាក់ដែលចេញដូចជាសងបំណុល បង់ថ្លៃបុគ្គលិក បង់ថ្លៃទឹកភ្លើង ឬសាលាកូនរៀនជាដើម គឺជាលំហូរសាច់ប្រាក់ចេញ។
  - ☞ របាយការណ៍បម្រែបម្រួលមូលធន (Statement Stockholder’s Exchange Equity) : របាយណ៍ការបម្រែបម្រួលមូលធនរបស់ម្ចាស់ (Stockholder’s Equity Change) គឺជារបាយណ៍ការមួយដែលបង្ហាញឱ្យឃើញពីរការផ្លាស់ប្តូរនូវមូលធនរបស់អង្គភាពអាជីវកម្ម នៅក្នុងកំឡុងគណនេយ្យ ឬចុងការិយបរិច្ឆេទថាវាមានការប្រែប្រួលកើនឡើង ឬថយចុះយ៉ាងដូចម្តេច។
  - ☞ របាយការណ៍កំណត់សម្គាល់ហិរញ្ញវត្ថុ (Note to the Financial Statement) : កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ បានពន្យល់បង្ហាញអំពី សមតុល្យគណនីដែលមាននៅលើរបាយការណ៍ហិរញ្ញវត្ថុ ការអនុលោមតាមស្តង់ដាណាមួយ គោលនយោបាយគណនេយ្យសំខាន់ៗ

និងព័ត៌មានផ្សេងទៀត ដូចជាព័ត៌មានបុគ្គលពាក់ព័ន្ធនឹងអង្គភាព ព្រឹត្តិការណ៍ក្រោយថ្ងៃតុល្យការជាដើម។

## ២.៣ សារៈសំខាន់របស់គណនេយ្យករ

### ២.៣.១ និយមន័យនៃសារៈសំខាន់

សារៈសំខាន់មានន័យថាចរិតលក្ខណៈអ្វីៗដែលធំមានប្រយោជន៍ដែលគួររិះគិតឡើងហ្មត់ចត់ដែលជាគួរយកជាគំរូដូចជាភាពអង់អាច សេចក្តីពិត សេចក្តីខ្ជាប់ខ្ជួន គុណភាពនៃភាពសក្តិសមយកចិត្តទុកដាក់[8]។

សារៈសំខាន់គឺជាសំណើរ ការទាមទារ ឬការអង្វរដែលអាចត្រូវបានគេយល់ថាជាការរំខាន ការរំខាន ឬការទទូច។ បុគ្គលដែលចូលរួមក្នុងការមិនយកចិត្តទុកដាក់អាចសុំអ្វីមួយម្តងហើយម្តងទៀត ឬព្យាយាមបញ្ចុះបញ្ចូលអ្នកដទៃឱ្យបំពេញបំណងរបស់ពួកគេ ជារឿយៗមិនយកចិត្តទុកដាក់លើព្រំដែន ឬចំណូលចិត្តរបស់ពួកគេ។ សារៈសំខាន់អាចជាពាក្យសំដី សរសេរ ឬបង្ហាញតាមរយៈសកម្មភាពដែលដាក់សម្ពាធលើអ្នកទទួលឱ្យធ្វើតាម។ ការដោះស្រាយការនាំចូលតម្រូវឱ្យកំណត់ព្រំដែនច្បាស់លាស់ ការប្រាស្រ័យទាក់ទងគ្នាដោយអះអាង និងដឹងថាពេលណាត្រូវនិយាយថាទេដោយអះអាង។ ភាពរសើបចំពោះអារម្មណ៍ និងតម្រូវការរបស់អ្នកដទៃ ខណៈពេលដែលការអះអាងអំពីព្រំដែនផ្ទាល់ខ្លួន គឺជារឿងចាំបាច់ក្នុងការគ្រប់គ្រងស្ថានភាពមិនអំណោយផល។

គណនេយ្យករ គឺមានសារៈសំខាន់សម្រាប់អាជីវកម្មដូចបុគ្គលិកប្រតិបត្តិការរបស់ខ្លួន។ អ្នកត្រូវការបុគ្គលិក ដើម្បីគ្រប់គ្រងលុយរបស់អ្នកនៅពេលដែលអាជីវកម្មរបស់អ្នករីកចម្រើន។ មូលហេតុនេះ ដែលអ្នកត្រូវការគណនេយ្យករមានសារៈសំខាន់ដូចជា៖

- ជួយសម្រួលដល់ការរៀបចំបញ្ជីផ្សេងៗរបស់ក្រុមហ៊ុនឱ្យមានរបៀបរៀបរយ
- បង្ហាញពីស្ថានភាពរបស់ក្រុមហ៊ុន ធ្វើឱ្យក្រុមហ៊ុនមានភាពងាយស្រួលក្នុងការរៀបចំ និងចេញសេក្តីសម្រេចផ្សេងៗ
- អាចបង្ហាញពីស្ថានភាពជាក់ស្តែងរបស់ក្រុមហ៊ុនថាចំណេយ ឬខាត
- ជួយគ្រប់គ្រងស្ថានភាពចំណូល និងចំណាយដែលបានកើតឡើងក្នុងក្រុមហ៊ុន ដែលអាចជួយឱ្យអ្នកគ្រប់គ្រងមានលទ្ធភាពក្នុងការកាត់បន្ថយនូវចំណាយដែលគ្មានប្រយោជន៍មួយចំនួនបាន
- ធ្វើការវិភាគ និងការពិចារណាអំពីគោលការណ៍ ផែនការ និងកំណត់នូវទិសដៅផ្សេងៗទៀតក្នុងក្រុមហ៊ុន
- អាចជួយការបន្ថយបាននូវការកេងប្រវ័ញ្ចផ្សេងៗបាន
- ជួយរៀបចំរបាយការណ៍ហិរញ្ញវត្ថុមួយដែលមានភាពត្រឹមត្រូវ និងស្រប់តាមស្តង់ដារក្នុងក្រុមហ៊ុន
- ផ្តល់ភាពងាយស្រួលនៅក្នុងការកំណត់មុខងារផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ធ្វើការបង់ពន្ធ និងធ្វើផែនការហិរញ្ញវត្ថុ

[8] *ដកស្រង់ពីវចនានុក្រមខ្មែររបស់សម្តេច សង្ឃរាជ ជួនណាត*

**២.៣.១ លក្ខណៈសម្បត្តិរបស់គណនេយ្យករ**

**ក.ការអប់រំ**

ការអប់រំ គណនេយ្យករជាធម្មតាមានបរិញ្ញាបត្រផ្នែកគណនេយ្យ ឬផ្នែកដែលពាក់ព័ន្ធ។ គណនេយ្យករខ្លះក៏អាចមានសញ្ញាបត្រអនុបណ្ឌិត ឬវិញ្ញាបនប័ត្រដូចជា CPA (Certified Public Accountant) ផងដែរ។

**ខ.វិញ្ញាបនប័ត្រ**

គណនេយ្យករជាច្រើនជ្រើសរើសដើម្បីក្លាយជាអ្នកបញ្ជាក់ ដូចជាការទទួលបានអាជ្ញាប័ណ្ណ CPA ឬវិញ្ញាបនប័ត្រឯកទេសផ្សេងទៀតដូចជា CMA (Certified Management Accountant) ឬ CIA (Certified Internal Auditor) ។

**គ.ជំនាញវិភាគ**

គណនេយ្យករត្រូវតែមានជំនាញវិភាគខ្លាំង ដើម្បីបកស្រាយទិន្នន័យហិរញ្ញវត្ថុ កំណត់និន្នាការ និងធ្វើការណែនាំដោយផ្អែកលើការវិភាគរបស់ពួកគេ។

**ឃ.យកចិត្តទុកដាក់លើព័ត៌មានលម្អិត**

គណនេយ្យករត្រូវតែតម្រង់ទិសលម្អិត ដើម្បីធានាបាននូវភាពត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ និងឯកសារផ្សេងៗទៀត។

**ង.ជំនាញទំនាក់ទំនង**

គណនេយ្យករត្រូវមានលទ្ធភាពប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយអតិថិជន សហសេវិក និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីពន្យល់ព័ត៌មានហិរញ្ញវត្ថុ និងផ្តល់អនុសាសន៍។

**ច. ជំនាញកុំព្យូទ័រ**

គណនេយ្យករត្រូវមានជំនាញក្នុងការប្រើប្រាស់កម្មវិធីគណនេយ្យ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដើម្បីគ្រប់គ្រង និងវិភាគទិន្នន័យ។

**ឆ. ស្តង់ដារសីលធម៌**

គណនេយ្យករត្រូវបានគេរំពឹងថា នឹងប្រកាន់ខ្ជាប់នូវស្តង់ដារសីលធម៌ខ្ពស់ និងរក្សាការសម្ងាត់នៅពេលដោះស្រាយព័ត៌មានហិរញ្ញវត្ថុដ៏រសើប។

**ជ. ជំនាញដោះស្រាយបញ្ហា**

គណនេយ្យករត្រូវតែអាចកំណត់អត្តសញ្ញាណ និងដោះស្រាយបញ្ហាហិរញ្ញវត្ថុ និងភាពមិនស្របគ្នាបានទាន់ពេលវេលា។

**ឈ. ការគ្រប់គ្រងពេលវេលា**

គណនេយ្យករតែងតែធ្វើការលើគម្រោងជាច្រើន និងពេលវេលាកំណត់ ដូច្នេះពួកគេត្រូវតែអាចកំណត់អាទិភាពការងារ និងគ្រប់គ្រងពេលវេលារបស់ពួកគេឱ្យមានប្រសិទ្ធភាព។

**ញ. ចំណេះដឹងអំពីបទប្បញ្ញត្តិ**

គណនេយ្យករ ត្រូវតែធ្វើបច្ចុប្បន្នភាពលើបទប្បញ្ញត្តិ និងច្បាប់ហិរញ្ញវត្ថុដើម្បីជានាបាននូវការអនុលោមតាមតម្រូវការរាយការណ៍ និងជៀសវាងបញ្ហាផ្លូវច្បាប់។

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុន ស្មាត អាស្យាតា ខូអិលធីឌី

## ៣.១ ស្ថានភាពទូទៅនៃក្រុមហ៊ុនផ្គត់ផ្គង់សេវាកម្ម Smart Axiata

ក្រុមហ៊ុន Smart Axiata Co., Ltd. ជាប្រតិបត្តិករទូរគមនាគមន៍ចល័តឈានមុនគេក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ន ក្រុមហ៊ុនបាននឹងកំពុងបម្រើអតិថិជនចំនួន ៨ លាននាក់ ស្ថិតក្រោមស្លាកសញ្ញា "Smart"។ Smart Axiata គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមេ មានឈ្មោះថា "Axiata Group Berhad" ដែលជាក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ធំជាងគេបង្អស់មួយក្នុងទ្វីបអាស៊ី។

ក្រុមហ៊ុន Smart គឺជាប្រតិបត្តិករទូរគមនាគមន៍ចល័ត ដែលមានភាពឈានមុខគេបង្អស់ ផ្នែកសេវាបច្ចេកវិទ្យាទំនើបទាន់សម័យក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុន Smart គឺជាប្រតិបត្តិករដំបូងបង្អស់ដែលបានដាក់ឱ្យដំណើរការសេវាបច្ចេកវិទ្យាជំនាន់ទី៤ "4G LTE" ក្នុងឆ្នាំ២០១៤ បច្ចេកវិទ្យា 4G LTE Advanced (ត្រូវបានគេស្គាល់ថា4G+)ក្នុងឆ្នាំ២០១៦ បច្ចេកវិទ្យា 4G LTE Advanced Pro(ត្រូវបានគេស្គាល់ថា4.5G) ជាមួយ HD Voice (VoLTE) ក្នុងឆ្នាំ២០១៧។ នៅពាក់កណ្តាលឆ្នាំ២០១៩ Smart បានរៀបចំកម្មវិធីបង្ហាញសាកល្បងបច្ចេកវិទ្យាជំនាន់ទី៥ "5G" ដំបូងគេបង្អស់នៅកម្ពុជា ដោយបង្ហាញពីភាពជាអ្នកដឹកនាំផ្នែកសេវាទិន្នន័យចល័ត។ ក្រុមហ៊ុន Smart ក៏មានផ្តល់នូវបច្ចេកវិទ្យាទូរស័ព្ទចល័តដ៏សម្បូរបែបរួមមាន៖ សេវាបច្ចេកវិទ្យា 2G, 2.5G, 3G និង3.75G ក៏ដូចជាសេវាកម្មទូរស័ព្ទក្រៅប្រទេស (Roaming) ដែលអាចប្រើបានច្រើនជា ១៩០ប្រទេស។ Smart បាននឹងកំពុងផ្តល់សេវា គ្របដណ្តប់ក្នុងតំបន់ប្រជាសាស្ត្រច្រើនជាង៩៩% (កៅសិបប្រាំបួន) ភាគរយ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនក៏កំពុងបម្លែងខ្លួនយ៉ាងសកម្មទៅជាប្រតិបត្តិករបែបឌីជីថល តាមរយៈការផ្តល់នូវសេវាកម្ម និងកម្មវិធីកំសាន្តលក្ខណៈស៊ីវិល័យប្រកបដោយភាពច្នៃប្រឌិតជាច្រើន។ នេះរួមបញ្ចូលភាពជាដៃគូជាមួយភាគីអន្តរជាតិនានាដូចជា៖ ក្រុមហ៊ុន Universal Music ក្រុមហ៊ុន Apple និងក្រុមហ៊ុន Facebook ក៏ដូចជាសេវាកម្មឌីជីថលនានារួមមាន៖ សេវា Pi Pay សេវាធានារ៉ាប់រងជីវិតឆ្លាតវៃយសេវា SmartPay សេវា Pleng by Smart និងសេវា SmartNas ។ ក្រុមហ៊ុន Smart មានទស្សនៈវិស័យក្លាយជាក្រុមហ៊ុន "លេខ១ និងជាក្រុមហ៊ុនបច្ចេកវិទ្យាទូរគមនាគមន៍ ដែលទទួលបានក្តីស្រលាញ់ពេញចិត្តបំផុត" នៅព្រះរាជាណាចក្រកម្ពុជា តាមរយៈកម្មវិធីទំនួលខុសត្រូវខ្ពស់លើកិច្ចការងារសង្គម និងកម្មវិធីនិរន្តរភាពនានា សម្រាប់កំណើនសេដ្ឋកិច្ច និងសង្គមជាតិ។

ក្រុមហ៊ុន Smart មានបុគ្គលិកនិយោជិតសរុបប្រមាណជាង១,០០០ (មួយពាន់)នាក់ ក្នុងនោះរួមបញ្ចូលទាំងនិយោជិតក្នុងស្រុក និងនិយោជិតបរទេស ដែលកំពុងខិតខំប្រឹងប្រែងឆ្ពោះទៅសម្រេចបេសកកម្មរួមគ្នាក្នុងការផ្សារភ្ជាប់ និងធ្វើឱ្យជីវិតកាន់តែប្រសើរឡើង។

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុនផ្គត់ផ្គង់សេវាកម្ម Smart Axiata

ក្រុមហ៊ុន Smart Axiata បានចាប់ផ្តើមដំណើរការក្នុងវិស័យទូរគមនាគន៍កម្ពុជា កាលពីខែកុម្ភៈ ឆ្នាំ ២០០៩ ក្រោមឈ្មោះ «Smart Mobile»។ ទោះជាការចាប់ផ្តើមដំបូង មានភាពសាមញ្ញក៏ដោយបន្តិចម្តងៗ ក្រុមហ៊ុនកាន់តែមានភាពលេចធ្លោតាមរយៈគោលការណ៍អាជីវកម្មថ្មីៗ និងទំនើប ដែលរួមមានតម្លៃសមរម្យ សេវាកម្មគួរឲ្យទាក់ទាញ និង្គយុទ្ធសាស្រ្តផ្តោតលើអតិថិជន។

នៅដើមឆ្នាំ២០១៣ ក្រុមហ៊ុន Smart បានធ្វើការរួមបញ្ចូលគ្នាជាមួយ Hello Axiata ហើយបានក្លាយជា «Smart Axiata» ដែលបានប្រែខ្លួនជាប្រតិបត្តិករទូរស័ព្ទចល័តធំជាងគេទីពីរ នៅក្នុងព្រះរាជាណាចក្រ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុន Smart Axiata ក៏បានក្លាយជាផ្នែកមួយនៃ Axiata Group ដែលជាសម្ព័ន្ធក្រុមហ៊ុនវិនិយោគទូរគមនាគន៍ធំជាងគេនៅអាស៊ី ដែលមានអតិថិជនជាង១៥០ លាននាក់នៅទូទាំង១១ ប្រទេស នៅតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូងផងដែរ។ ក្នុងនាមជាក្រុមហ៊ុនទូរគមនាគមន៍ឈានមុខគេក្នុងប្រទេសកម្ពុជា ក្រុមហ៊ុន Smart Axiata Co., Ltd. គឺជាប្រតិបត្តិករទូរស័ព្ទចល័តដំបូងគេក្នុងប្រទេសកម្ពុជាដែលផ្តល់សេវា 4G ។ សេវា 4G LTE របស់ក្រុមហ៊ុន Smart ដែលផ្តល់អ៊ិនធឺណិតចល័តលឿនបំផុត ក្នុងប្រទេសកម្ពុជាឥឡូវនេះមាននៅទូទាំង២៥ ខេត្តក្រុង។ ក្រុមហ៊ុន Smart ក៏ជាក្រុមហ៊ុនដំបូងគេនៅក្នុងព្រះរាជាណាចក្រ ដែលបានសាកល្បងបច្ចេកវិទ្យា 5G លើកដំបូងមិនធ្លាប់មាននៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ២០១៩។ ផលិតផល និងសេវាកម្មរបស់ Smart Axiata តែងតែទទួលបាននូវការគាំទ្រ ជាពិសេស ពីសំណាក់យុវវ័យជំនាន់ក្រោយ ដែលនិយមនូវការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនានា។

លោក Ziad Shatara នាយកប្រតិបត្តិនៃក្រុមហ៊ុន Smart Axiata បានលើកឡើងថា Smart តែងតែព្យាយាមក្នុងការអភិវឌ្ឍ និងការបង្កើតថ្មី ដើម្បីផ្តល់ជូននូវគុណតម្លៃពិសេសទៅកាន់អតិថិជន ភ្នាក់ងារលក់រាយ ដៃគូអាជីវកម្ម និងភាគីពាក់ព័ន្ធផ្សេងៗ។ យើងរក្សានូវគុណតម្លៃរបស់យើងជាអាជីវកម្មដែលមានទំនួលខុសត្រូវសង្គម តាមរយៈការអនុវត្តដ៏ល្អរបស់យើង សុចរិតភាព និងតម្លាភាពដែលមិនអាចកាត់ថ្លៃបាន។ លោកក៏បានបន្តទៀតថា "ជាមួយនឹងកម្លាំងចិត្តពី ភាពជោគជ័យជាបន្តបន្ទាប់របស់យើង យើងនឹងខិតខំប្រឹងប្រែង បន្តទៀតដើម្បីធានាឲ្យមានការផ្លាស់ប្តូរយូរអង្វែង និងនិរន្តរភាព តាមរយៈកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងៗ"។

### ៣.១.២ បេសកកម្ម ទស្សនៈ និងគុណតម្លៃរបស់ក្រុមហ៊ុនផ្គត់ផ្គង់សេវាកម្ម Smart Axiata

បេសកកម្ម ទស្សនវិស័យ និងគុណតម្លៃស្នូលរបស់ក្រុមហ៊ុន ស្មាតអាស្យាតាគឺជាគោលការណ៍ណែនាំសម្រាប់ឱ្យបុគ្គលិកទាំងអស់ នៅស្មាតយល់ពីគោលដៅរបស់យើងទាំងអស់គ្នា។ ពួកយើងទាំងអស់គ្នា នៅស្មាតត្រូវតែសម្របខ្លួនឯងទៅនឹងគោលការណ៍ និងគោលដៅទាំងអស់នេះ ដើម្បីបង្កើតនូវបរិយាកាសដែលប្រកបទៅដោយគុណតម្លៃ ដែលល្អសាកសមសម្រាប់ភ្ញៀវដ៏ជាទីគោរពរបស់ពួកយើង។

#### ក. បេសកកម្ម

- ធ្វើការបម្រើអតិថិជនទាន់ពេលវេលា
- មានទំនួលខុសត្រូវខ្ពស់ចំពោះអតិថិជន

- ប្រកាន់ភ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ
- យើងភ្ជាប់ទំនាក់ទំនងរបស់លោកអ្នក។
- យើងធ្វើឱ្យជីវិតលោកអ្នកកាន់តែប្រសើរឡើង។

**ខ. ទស្សនៈ**

- រិះរកយុទ្ធសាស្រ្តដើម្បីឱ្យប្រាក់ចំណូលរបស់ក្រុមហ៊ុនកើនឡើងជានិច្ច
- ខិតខំពង្រីកវិសាលភាពរបស់ក្រុមហ៊ុន
- បង្កើតឱ្យមានសេវាកម្មទាំងក្នុងស្រុក និងក្រៅស្រុក
- ពង្រឹងខ្លួនឱ្យនៅតែកាន់ជិតអតិថិជន
- យើងនឹងក្លាយជាក្រុមហ៊ុនបច្ចេកវិទ្យា ទូរគមនាគមន៍ចំណាត់ថ្នាក់លេខ១ នឹងទទួលបានក្តីស្រឡាញ់បំផុតក្នុងប្រទេសកម្ពុជា។

**គ. គុណតម្លៃក្នុងក្រុមហ៊ុន**

**ពួកយើងបើកចំហរ និងស្មោះត្រង់**



- ខ្ញុំប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌របស់ក្រុមហ៊ុន។
- ខ្ញុំមានភាពស្មោះត្រង់ និងតម្លាភាពរវាងគ្នាទៅវិញទៅមក។
- ខ្ញុំស្តាប់មុននឹងឆ្លើយតប និងទទួលយកនូវមតិស្ថាបនា។

**ពួកយើងទទួលបានជោគជ័យ យ៉ាងធំជាក្រុម**



- ខ្ញុំធ្វើតាមការសន្យារបស់ខ្ញុំ ដើម្បីសម្រេចគោលដៅរួមរបស់យើង។
- ខ្ញុំយកចិត្តទុកដាក់លើអ្វីៗដែលអ្នកដទៃធ្វើ។

**ពួកយើងគឺអង់អាចក្លាហាន**



- ខ្ញុំហ៊ានជម្រុញខ្លួនឯង និង អ្នកដទៃឲ្យប្រតិបត្តិការងារ ដោយប្រើវិធីថ្មីៗដែលប្រសើរជាងមុន។
- ខ្ញុំរៀនពីកំហុសរបស់ខ្ញុំដើម្បីបន្តដំណើរទៅមុខ។

**ពួកយើងគឺខិតខំមុតមាំ**



- ខ្ញុំប្រឹងប្រែងធ្វើអ្វីដែលលើសពីការរំពឹងទុក។
- ខ្ញុំប្រតិបត្តិការងារដោយភាពស្វាហាប់ និង ការប្តេជ្ញាអស់ពីចិត្តពីកាយ។

### ឃ. ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន Smart Axiata

ក្រុមហ៊ុន Smart Axiata ដែលជាប្រតិបត្តិករទូរគមនាគមន៍ចល័តឈានមុខគេនៅកម្ពុជា បានបញ្ជាក់ម្តងទៀត នូវការប្តេជ្ញាចិត្តរយៈពេលវែងរបស់ខ្លួន ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា តាមរយៈការចេញផ្សាយរបាយការណ៍និរន្តរភាពឆ្នាំ២០២០ របស់ខ្លួន ដែលរួមបញ្ចូលព័ត៌មានលម្អិតអំពីការចូលរួមចំណែករបស់ក្រុមហ៊ុនទៅកាន់សេដ្ឋកិច្ច និងអនាគតឌីជីថលរបស់ប្រទេសកម្ពុជា។

យោងតាមការចេញផ្សាយរបាយការណ៍និរន្តរភាព២០២០ ប្រចាំឆ្នាំរបស់ខ្លួនក្រុមហ៊ុន Smart Axiata បានបង់ពន្ធចំនួន៩៥ លានដុល្លារ លើពន្ធអាករ និងកម្រៃនិយ័តកម្មនៅឆ្នាំ២០២០ ហើយនៅតែបន្តជាជម្រើសនៃនិយោជក ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគាំទ្រដល់ការងារចំនួន៥៦ ពាន់កន្លែងក្នុងឆ្នាំ២០២០ ដោយផ្ទាល់ ឬតាមរយៈការវិនិយោគរបស់ខ្លួននោះទេ។

របាយការណ៍នេះ ក៏បានគូសបញ្ជាក់ផងដែរថា គិតត្រឹមដំណាច់ឆ្នាំ២០២០ ក្រុមហ៊ុន Smart Axiata បានវិនិយោគទឹកប្រាក់ប្រមាណ១,៨៨ ពាន់លានដុល្លារ លើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងសម្រាប់ប្រទេសកម្ពុជា និងបានរួមចំណែកជាង៥៦២ លានដុល្លារទៅក្នុងពន្ធអាករ និងកម្រៃនិយ័តកម្មដល់រាជរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីក្រុមហ៊ុនបានចាប់ផ្ដើមដំណើរការក្នុងឆ្នាំ២០០៨ មកម្ល៉េះ។

សម្រាប់ក្រុមហ៊ុន Smart Axiata របៀបវារៈដ៏សំខាន់របស់ខ្លួនក្នុងការអភិវឌ្ឍន៍កម្ពុជា គឺជាការប្ដេជ្ញាចិត្តក្នុងការបង្កើអនាគតឌីជីថលរបស់កម្ពុជា ជាមួយនឹងការវិនិយោគជាបន្តបន្ទាប់ ទៅលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនានាក៏ដូចជា ការគាំទ្រដល់អាជីវកម្មឌីជីថលទើបបង្កើតថ្មី និង "សហគ្រិនបច្ចេកវិទ្យា" របស់កម្ពុជា។ ដោយបានដាក់សាកល្បង ប្រកបដោយជោគជ័យនូវបច្ចេកវិទ្យ5G នៅប្រហែល២០ កន្លែង ក្នុងរាជធានីភ្នំពេញ ក្រុមហ៊ុន Smart នឹងសហការជាមួយអាជ្ញាធរយ៉ាងជិតស្និត ក្នុងការដាក់ឱ្យដំណើរការបច្ចេកវិទ្យា 5G នៅក្នុងប្រទេសកម្ពុជា ដើម្បីនាំមុខក្នុងការផ្ដល់លទ្ធភាពឱ្យកាន់តែទូលំទូលាយ ក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យាដ៏គួរឱ្យរំភើបនេះក្នុងប្រទេសកម្ពុជា។

នាយកប្រតិបត្តិស្ដីទីរបស់ Smart Axiata លោក Feiruz Ikhwan បានមានប្រសាសន៍ថា៖ យើងបន្តធ្វើការយ៉ាងមុតមាំ ដើម្បីជួយត្រួសត្រាយផ្លូវ សម្រាប់យុគសម័យឌីជីថលរបស់កម្ពុជា។ ក្នុងនាមជា ប្រតិបត្តិករទូរគមនាគមន៍ចល័តឈានមុខគេក្រុមហ៊ុន Smart នឹងព្យាយាមប្រើប្រាស់ឯកទេសដ៏ខ្លាំង និងធនធានរបស់ពួកយើង ព្រមទាំងសហការជាមួយក្រសួងពាក់ព័ន្ធនានា នៃរាជរដ្ឋាភិបាលកម្ពុជាដើម្បីជួយប្រទេសកម្ពុជាក្នុងអំឡុងពេលដ៏លំបាកនេះ។ នៅក្រុមហ៊ុន Smart Axiata យើងយល់ថានេះ គឺជាបេសកកម្មរបស់ពួកយើង ក្នុងការបន្តភ្ជាប់ទំនាក់ទំនងរបស់ប្រជាជនកម្ពុជា និងការវិនិយោគលើផ្នែកនានា ដែលផ្ដល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា ជាពិសេស ក្នុងពេលកសាងអនាគតឌីជីថលដ៏មានឥទ្ធិពលរបស់ព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងរបាយការណ៍និរន្តរភាព ដែលមានចំណងជើងថា ការបង្កើតទំនាក់ទំនងដ៏មានអត្ថន័យ សម្រាប់អនាគតប្រកបដោយនិរន្តរភាព។ ក្រុមហ៊ុន Smart បង្ហាញពីសកម្មភាពជាច្រើនទៀត ដែលឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្ត ក្នុងការក្លាយជាអាជីវកម្ម ដែលមើលមិនត្រឹមតែប្រាក់ចំណេញនោះទេ។ សកម្មភាពទាំងឡាយនោះរួមមានការដោះស្រាយយ៉ាងសកម្ម នូវបញ្ហាបម្រែបម្រួលអាកាសធាតុដោយដាក់នូវការត្រួតពិនិត្យ និងការគ្រប់គ្រង តាមដានការបញ្ចេញកាបូនរបស់ក្រុមហ៊ុនការរក្សានូវកម្រិតខ្ពស់បំផុត នៃសុចរិតភាពក្នុងប្រតិបត្តិការទាំងអស់ជាមួយអ្នកផ្គត់ផ្គង់ អ្នកចែកចាយ និងអតិថិជន និងគាំទ្រអ្នកផ្គត់ផ្គង់ក្នុងស្រុក។

របាយការណ៍នេះ ក៏បង្ហាញពីការខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុន Smart ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សដែលមិនត្រឹមតែផ្ដល់អត្ថប្រយោជន៍ដល់ក្រុមហ៊ុន Smart ប៉ុណ្ណោះទេ ថែមទាំងផ្ដល់អត្ថប្រយោជន៍ដល់ប្រទេសជាតិទាំងមូលផងដែរ។ ជាពិសេស ក្រុមហ៊ុនខិតខំបង្កើនគោលការណ៍ស្របតាមរបៀបវារៈ នៃសេដ្ឋកិច្ចឌីជីថលរបស់រដ្ឋាភិបាលដោយផ្ដោតលើការអភិវឌ្ឍន៍ និងការទទួលស្គាល់ជំនាញរបស់និយោជិតរបស់ខ្លួនតាមរយៈកម្មវិធីអភិវឌ្ឍន៍ទេពកោសល្យនានា និងកិច្ចសហប្រតិបត្តិការជាមួយដៃគូរបស់យើង ដើម្បីផ្ដល់ឱកាសអភិវឌ្ឍ និងសិក្សាដល់យុវជនកម្ពុជា ដើម្បីពួកគេអាចចូលរួមក្នុងសេដ្ឋកិច្ចឌីជីថលរបស់កម្ពុជា។

ក្រុមហ៊ុន Smart Axiata ក៏បាននាំមុខគេក្នុងការជួយជំរុញអ្នកលេងហ្គេមអេឡិចត្រូនិចនៅកម្ពុជាឱ្យបង្កើតភាពល្បីល្បាញនៅលើឆាកអន្តរជាតិផងដែរ ដោយក្រុមហ៊ុនបានផ្តើមកម្មវិធីប្រកួតកីឡាអេឡិចត្រូនិច ដ៏ធំបំផុតរបស់ព្រះរាជាណាចក្រកម្ពុជា និងបានចាប់ដៃគូជាមួយអ្នកបង្កើតហ្គេមអេឡិចត្រូនិចក្នុងស្រុក និងអន្តរជាតិផងដែរ ដើម្បីចែកចាយហ្គេម ដែលមនុស្សចូលចិត្តលេងនៅលើបណ្តាញអ៊ិនធឺណិតលឿនរហ័ស និងគួរឱ្យទុកចិត្ត។

កម្មវិធីផ្តួចផ្តើម ដ៏ទៃទៀតមានដូចជា ការបង្កើតមូលនិធិទឹកប្រាក់១លានដុល្លារដើម្បីប្រឆាំងកូវីដ១៩របស់ Smart Axiata ដើម្បីគាំទ្រដល់ដំណោះស្រាយ ដែលមានប្រសិទ្ធភាពខ្ពស់ ចំពោះបញ្ហាប្រឈមដែលប្រជាជនកម្ពុជា ជួបប្រទះក្នុងអំឡុងពេលជំងឺរាតត្បាតជាសកល។ មូលនិធិបានគាំទ្រគំនិតផ្តួចផ្តើមចំនួន១៣ផ្សេងៗគ្នាមកទល់ពេលនេះ។ ការបង្កើតរួមគ្នានៃពិព័រណ៍ជំនាញសិក្សា និងការងារតាមប្រព័ន្ធអនឡាញជាមួយសមាគម អតីតនិស្សិតអាហារូបករណ៍សហរដ្ឋអាមេរិក Fulbright ថ្នាក់បរិញ្ញាបត្រ (FUSAAC) កម្មវិធីអាហារូបករណ៍ SmartEdu ដែលបានផ្តល់ថវិកាចំនួន៣ សែនដុល្លារ ចាប់តាំងពីការបង្កើតឡើង ក្នុងឆ្នាំ២០១៦ មកហើយ និងមូលនិធិគ្រោះទឹកជំនន់របស់ក្រុមហ៊ុន Smart Axiata ដែលប្រមូលបានជា៦.៦ ម៉ឺនដុល្លា សម្រាប់ក្រុមគ្រួសាររងផលប៉ះពាល់ពីគ្រោះទឹកជំនន់កាលពីចុងឆ្នាំ២០២០។

លោក Feiruz មានប្រសាសន៍ថា៖ នៅក្រុមហ៊ុន Smart Axiata យើងលើកទឹកចិត្តក្រុមការងាររបស់យើងឱ្យដឹកនាំប្រកបដោយគំរូ។ ដោយសារហេតុផលនេះ ទើបយើងដាក់ចេញនូវនិតិវិធីអំពីជំងឺកូវីដ១៩ ដ៏មឺងម៉ាត់ ដើម្បីរក្សាប្រតិបត្តិការប្រចាំថ្ងៃរបស់យើង ដើម្បីជាប្រយោជន៍អតិថិជនរបស់យើងទាំងអស់។ យើងក៏បានផ្តល់អាទិភាពដល់សុខុមាលភាពរបស់និយោជិត ដោយរៀបចំការិយាល័យបន្ថែមដើម្បីអនុញ្ញាតឱ្យមានគម្លាតរវាងនិយោជិតត្រឹមត្រូវក្នុងប្រតិបត្តិការការងារ ហើយយើងបន្តអនុវត្តយ៉ាងតឹងរឹង នូវនីតិវិធីសុវត្ថិភាពនៅកន្លែងធ្វើការរបស់យើងផងដែរ។

ដោយក្រឡេកមើលទៅលើការចូលរួមចំណែក និងសមិទ្ធផលសំខាន់ៗអំឡុងឆ្នាំ២០២០ របាយការណ៍និរន្តរភាពឆ្នាំ ២០២០ របស់ក្រុមហ៊ុន Smart Axiata គូសបញ្ជាក់អំពីបេសកកម្មរបស់ក្រុមហ៊ុន គឺផ្តោតលើ “យើងភ្ជាប់ទំនាក់ទំនងយើងធ្វើឱ្យជីវិតកាន់តែប្រសើរឡើង” និងចក្ខុវិស័យសម្រាប់អនាគត៖ “ដើម្បីក្លាយជាយីហោក្រុមហ៊ុនបច្ចេកវិទ្យាទំនាក់ទំនងលេខ១ និងជាទីពេញចិត្តបំផុតក្នុងប្រទេសកម្ពុជានៅឆ្នាំ២០២២”។

លោក Feiruz ក៏បន្ថែមទៀតថា យើងមានមោទនភាពចំពោះការចូលរួមចំណែករបស់យើង ក្នុងកំណើននិងការអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា ដែលជាផ្ទះរបស់យើង ហើយយើងសូមថ្លែងអំណរគុណចំពោះដៃគូ អ្នកពាក់ព័ន្ធរបស់យើងទាំងអស់ និងរាជរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា ចំពោះការបន្តគាំទ្ររបស់លោកអ្នក។ យើងនឹងបន្តដើរតួនាទីយ៉ាងស្វាហាប់ ក្នុងនាមជាអ្នកជំរុញសក្តានុពលឌីជីថល និងបង្កើតការភ្ជាប់បណ្តាញទំនាក់ទំនងដ៏មានអត្ថន័យ ខណៈពេលដែលការបើកឱ្យមានអនាគតវិជ្ជមាន និងនិរន្តរភាពសម្រាប់សហគមន៍ និងប្រទេសរបស់យើង។

### ខ. របាយការណ៍និរន្តរភាពរបស់ក្រុមហ៊ុន Smart Axiata

នៅក្រុមហ៊ុន Smart Axiata យើងមិនត្រឹមតែជាប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនបច្ចេកវិទ្យាឈានមុខគេប៉ុណ្ណោះទេ យើងប្តេជ្ញាធ្វើឱ្យមានការផ្លាស់ប្តូរដ៏ល្អមួយយ៉ាងពិតប្រាកដយើងបានពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីបង្កើតផលវិជ្ជមានយូរអង្វែងសម្រាប់សហគមន៍បរិស្ថាន និងប្រជាជនកម្ពុជា។ ការប្តេជ្ញាចិត្តរបស់យើង គឺលើសពីប្រាក់ចំណេញរយៈពេលខ្លី ជាមួយនឹងគោលបំណងរបស់យើងផ្តោតលើការកសាងកំណើនដំណែលយូរអង្វែង។ តម្លៃស្នូលរបស់យើងគឺ សុចរិតភាពដែលមិនអាចកាត់ថ្លៃបាន ដំណើរការដ៏ល្អលើសពីការរំពឹងទុក ភាពក្លាហាន ការប្តេជ្ញាចិត្ត និងការយកចិត្តទុកដាក់យ៉ាងល្អិតល្អន់ ដើម្បីធ្វើឱ្យបច្ចេកវិទ្យាមានលក្ខណៈសាមញ្ញសម្រាប់មនុស្សគ្រប់គ្នា។ គុណតម្លៃទាំងនេះជាមគ្គុទេសលើ បេសកកម្មរបស់យើង ក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យប្រទេសកម្ពុជាមានទំនាក់ទំនងល្អ និងលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។ ដោយឈរលើសសរសម្គនិរន្តភាពរបស់យើង កិច្ចខិតខំប្រឹងប្រែងប្រកបដោយនិរន្តរភាពរបស់យើងជំរុញយើងឆ្ពោះទៅរក "ជំរុញអនាគតប្រកបដោយនិរន្តរភាព" សម្រាប់ព្រះរាជាណាចក្រ។ វិធីសាស្ត្ររបស់យើងចំពោះនិរន្តរភាពគឺស្របតាម Axiata Group និងផ្អែកលើសសរស្តម្ភនិរន្តរភាពចំនួនបួន៖

លើសពីប្រាក់ចំណេញរយៈពេលខ្លី៖ យើងធ្វើការដើម្បីផ្តល់អត្ថប្រយោជន៍ដល់សហគមន៍តាមរយៈអាជីវកម្មរបស់យើង ការវិនិយោគនៅក្នុងសេដ្ឋកិច្ចក្នុងតំបន់ ហេដ្ឋារចនាសម្ព័ន្ធ និងបរិយាបន្នផ្នែកឌីជីថល។

ការបណ្តុះបណ្តាលធនធានមនុស្ស៖ យើងផ្តល់តម្លៃដល់ប្រជាជនរបស់យើង ដោយធានាថាកន្លែងធ្វើការពោរពេញទៅដោយសុវត្ថិភាព លើកកម្ពស់ចម្រុះភាព និងការវិនិយោគលើការសិក្សា និងលូតលាស់របស់ក្រុមការងាររបស់យើង ដើម្បីរក្សាបាននូវកម្លាំងពលកម្មដែលមានកម្លាំងចិត្ត និងមានការប្តេជ្ញាចិត្តខ្ពស់។

ដំណើរការល្អឥតខ្ចោះ៖ យើងបង្កើតការជឿទុកចិត្តពីសំណាក់អ្នកពាក់ព័ន្ធ ផ្តល់អាទិភាពដល់ភាពសុចរិតនៅក្នុងឧត្តមភាពឌីជីថលរបស់យើង និងពិចារណាលើផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គម (EES) ក្នុងប្រតិបត្តិការរបស់យើង។

ពិភពលោក និងសង្គម៖ យើងកាត់បន្ថយផលប៉ះពាល់បរិស្ថានរបស់យើង និងគាំទ្រសហគមន៍សម្រាប់អនាគតប្រកបដោយនិរន្តរភាព។

ក្រុមហ៊ុន Smart បាននឹងកំពុងធ្វើឱ្យមានភាពរីកចំរើន និងសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា តាមរយៈគំនិតផ្តួចផ្តើម និងកម្មវិធីជាច្រើន។ យើងផ្តោតលើការធានាឲ្យបានថា អ្នកគ្រប់គ្នានៅក្នុងប្រទេសមានលទ្ធភាពប្រើប្រាស់សេវាកម្មទំនាក់ទំនង សូម្បីតែនៅក្នុងតំបន់ដាច់ស្រយាលបំផុត ក៏ដោយ។ តាមរយៈភាពជាដៃគូ និងការសហការផ្សេងៗ ទាំងក្នុងវិស័យឯកជន និងស្ថាប័នរដ្ឋ យើងបានធ្វើការយកចិត្តទុកដាក់ ដើម្បីគាំទ្រកម្មវិធីសង្គមដែលឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ ដោយភ្ជាប់ទំនាក់ទំនងរវាងផ្នែកឌីជីថល និងការលើកកម្ពស់ចំណេះដឹងផ្នែកឌីជីថល។ យើងលើកកម្ពស់ចំណេះដឹង និងកម្មវិធីដែលទាក់ទងនឹងបច្ចេកវិទ្យា ស្របគ្នានឹងការជំរុញឲ្យប្រព័ន្ធអេកូឡូស៊ីផ្នែកបច្ចេកវិទ្យាកាន់តែប្រសើរឡើង ដែលជាសមាសធាតុសំខាន់ សម្រាប់ការធ្វើដំណើររបស់ប្រទេសឆ្ពោះទៅកាន់សេដ្ឋកិច្ច និងសង្គមឌីជីថល ប្រកបដោយបរិយាបន្ន។

គោលដៅរបស់យើង គឺកសាងនូវមូលដ្ឋានគ្រឹះ និងគាំទ្រដល់មហិច្ឆតារបស់កម្ពុជាក្នុងការក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ដោយធានាឲ្យបានថាមិនទុកនរណាម្នាក់ចោលឡើយ។ ដោយក្នុងការរួមចំណែក នៃការអភិវឌ្ឍន៍នេះ នៅក្នុងឆ្នាំ២០២២ ក្រុមហ៊ុន Smart បានបណ្ដាក់ទុនជាង 650,000 ដុល្លារអាមេរិកលើគំនិតផ្ដួចផ្ដើម និងសកម្មភាពសហគមន៍ ដែលផ្ដោតលើភាពជឿនលឿនផ្នែកឌីជីថល បច្ចេកវិទ្យា ការអប់រំ សហគ្រិនភាព និងការការពារបរិស្ថាន។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រងក្នុងក្រុមហ៊ុន Smart

❖ **រចនាសម្ព័ន្ធគ្រប់គ្រង**

✦ **លោក Ziad SHATARA**



នាយកប្រតិបត្តិការ

លោក Ziad ត្រូវបានតែងតាំងជាអគ្គនាយកក្រុមហ៊ុន Smart Axiata កាលពីខែមករាឆ្នាំ២០២៣។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយ ក្នុងការគ្រប់គ្រង និង ពន្លឿនកំណើនអាជីវកម្មទូរគមនាគមន៍នៅតាមទីផ្សារផ្សេងៗ រួមមាន ហ្សកដានី បង់ក្លាដែស និងអ៊ីតាលី។ គាត់ក៏មានកំណត់ត្រា តាមដានដែលបានបញ្ជាក់ពីការបង្កើតការគ្រប់គ្រង និងពង្រីកប្រតិបត្តិការទូរគមនាគមន៍រួមមានអាជីវកម្ម ទូរស័ព្ទដៃខ្សែថេរ និងការបញ្ចូលបណ្ដាញរលកអាកាស។ លោក Ziad ក៏មានបទពិសោធន៍យ៉ាងច្រើនក្នុង វិស័យបច្ចេកវិទ្យាព័ត៌មានសេវាកម្មអតិថិជន និងប្រតិបត្តិការលក់រាយមុនពេលចូលរួម Smart គាត់បានកាន់តំណែងគ្រប់គ្រងសំខាន់ៗ នៅក្នុងក្រុមហ៊ុនបច្ចេកវិទ្យាទំនាក់ទំនងជាច្រើន។ លោកជាប្រធានផ្នែកបច្ចេកវិទ្យា នៅទូរគមនាគមន៍ វីនអ៊ីនធីនិក មុននឹងក្លាយជាអគ្គនាយកនៃក្រុមហ៊ុន Digital Communications Brand Banglalink នៅទីក្រុង Dhaka ប្រទេស បង់ក្លាដេស។ គាត់បានចំណាយ ពេលប្រាំពីរឆ្នាំចុងក្រោយនេះ ជាប្រធានប្រតិបត្តិនៃក្រុមហ៊ុនផ្តល់បណ្តាញទូរស័ព្ទចល័តឈានមុខគេ របស់ប្រទេសចូដង់ អ៊ូមនីយ៉ា ចល័តដែលជាប្រតិបត្តិការ ទូរគមនាគមន៍ដែលកំពុងកើនឡើងលឿនបំផុតរបស់ ប្រទេស ចូដង់ ក្នុងពេលកំណត់ត្រា ។លោក Ziad កាន់បរិញ្ញាបត្រផ្នែកវិស្វកម្មអគ្គិសនី និងកុំព្យូទ័រពី សាកលវិទ្យាល័យ Budapest University of Technology and Economics។

✦ **អ្នកស្រី AIDA AHMAD DAUD**

នាយកប្រធានផ្នែកហិរញ្ញ



Aida បានចូលរួម Smart Axiata ជាប្រធានហិរញ្ញវត្ថុរបស់យើងនៅខែមេសា ឆ្នាំ២០២២។ មុនពេលកាន់តួនាទីនេះលោក Aida បានបម្រើការជានាយកហិរញ្ញវត្ថុនៅ Edotco Malaysia និងជាប្រធានហិរញ្ញវត្ថុយុទ្ធសាស្ត្រនៅក្រុមហ៊ុន Edotco។ មានបទពិសោធន៍ជាង២៥ ឆ្នាំក្នុងវិស័យទូរគមនាគមន៍ Aida បានកាន់មុខតំណែងជាថ្នាក់ដឹកនាំជាច្រើននៅក្នុងក្រុម Axiata ហើយ

ធ្លាប់ជាប្រធានក្រុមហិរញ្ញវត្ថុសាជីវកម្មនៅ Dialog Axiata (ស្រីលង្កា)។ តួនាទីរបស់នាងមានភាពខុសគ្នាពី M&A, Performance Management, Risk Management, Corporate Finance, Finance Operation, Cost Management and Group Business Planning. ក្នុងអំឡុងពេលធ្លាក់ចុះនៃ Telekom Malaysia និង TM International នៅ ឆ្នាំ២០០៨ នាងគឺជាប្រធានផែនការអាជីវកម្មក្រុមនៅក្រុមហ៊ុន Axiata Group។ Aida កាន់ Bachelor of Arts, Hon (Accountancy Studies) ពីសាកលវិទ្យាល័យ Exeter ចក្រភពអង់គ្លេស និងបានបញ្ចប់កម្មវិធី ដឹកនាំជាមួយកម្មវិធី INSEAD និង Harvard Leadership Program ពី Harvard Business Publishing ក្រោមកម្មវិធី Axiata Talent Program.

**✦ លោកស្រី MILA JIVKOVA KUSHEVA**

នាយកប្រធានផ្នែកទីផ្សារ



**MILA**បានចូលរួមជាមួយក្រុមហ៊ុន Smart Axiata នៅដើមឆ្នាំ២០២១។ មីឡាមានបទពិសោធន៍ជាច្រើនក្នុងវិស័យទូរគមនាគមន៍ តាមរយៈការងាររបស់គាត់នៅក្រុមហ៊ុនទូរគមនាគមន៍ពហុជាតិចំនួន៣ – OTE, Deutsche Telecom and Norwegian Telenor។ តួនាទីរបស់គាត់មានចម្រុះពីការវិភាគអាជីវកម្ម រហូតដល់ការអភិវឌ្ឍផលិតផល ដំណើរជីវិតរបស់អតិថិជន ការគ្រប់គ្រងតម្លៃ អន្តរកម្មឌីជីថលនិង ការអភិវឌ្ឍឆានែល។ មុនពេលចាប់ផ្តើមតួនាទីនៅ Smart មីឡាគឺជានាយកផ្នែកទីផ្សារនៅក្រុមហ៊ុន Telenor Bulgaria and Telenor Hungary។

ជាអ្នកជំនាញធ្វើទីផ្សារម្នាក់ **MILA** គឺតែងប្តេជ្ញាចិត្តក្នុងការច្នៃផលិតផលដែលផ្តល់នូវប្រយោជន៍ និងផ្តោតទៅលើអតិថិជន ដែលប្រកបដោយភាពងាយស្រួលនិងមានប្រសិទ្ធភាព។ ការធ្វើការងារជាក្រុម និងការចូលរួមឆ្លងក្រុម គឺជាគោលការណ៍ចំបងរបស់មីឡានៅពេលប្រព្រឹត្តិការងារប្រចាំថ្ងៃ។ មីឡាមានជំនឿថាលទ្ធផលទីផ្សារអាចប្រសើរឡើងបានតាមរយៈការអភិវឌ្ឍសមត្ថភាព និងជំនាញរបស់សមាជិកក្រុមរបស់គាត់។

**MILA** ទទួលបានអនុបណ្ឌិតផ្នែកការទូតនិងទំនាក់ទំនងអន្តរជាតិពី University of Sofia ព្រមទាំងវិញ្ញាបនប័ត្រខ្សែក្រវ៉ាត់ខ្មៅ (Black Belt certification) ។ គាត់ក៏មានបរិញ្ញាបត្រក្រោយឧត្តមសិក្សាក្នុងការច្នៃប្រឌិតក្នុងសេដ្ឋកិច្ចឌីជីថលពី INSEAD និង ការអនុវត្តយុទ្ធសាស្រ្តពី London Business School។

## ៣.២ តួនាទីគណនេយ្យករក្នុងក្រុមហ៊ុន Smart

### ៣.២.១ ភារកិច្ចគណនេយ្យករ

គណនេយ្យករ ចាំបាច់ណាស់ត្រូវតែធ្វើការកត់ត្រាប្រចាំថ្ងៃរាល់ប្រតិបត្តិការទាំងអស់ ដែលបានកើតឡើងក្នុងក្រុមហ៊ុនដូចជា៖

- បញ្ចូលទិន្នន័យ បើកប្រាក់ពីឯកសារវេណាទានទៅក្នុងប្រព័ន្ធកុំព្យូទ័រ នៅពេលដែលមានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ។
- ចុះបញ្ជីគណនេយ្យ ផ្អែកតាមសក្ខីបត្រស្របច្បាប់។

- បញ្ចូលទិន្នន័យក្នុងកម្មវិធីកុំព្យូទ័រតាមប្រតិបត្តិការសេដ្ឋកិច្ចកើតឡើងប្រចាំថ្ងៃដោយ និងត្រឹមត្រូវតាមប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុន។
- ត្រួតពិនិត្យផ្ទៀងផ្ទាត់ នូវរាល់សមតុល្យសាច់ប្រាក់ ដែលមានជាក់ស្តែងជាមួយបេឡាធិការធៀបនឹងសមតុល្យដែលមានក្នុងបញ្ជីរៀងរាល់ថ្ងៃ។
- ការដាក់ប្រាក់ ឬដកប្រាក់ និងការសងប្រាក់។
- កត់ត្រាប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃរបស់ក្រុមហ៊ុន៖ កត់ត្រាការលក់ចេញ ការទិញចូល និងចំណាយផ្សេងៗទៀត។
- គ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន ៖ ត្រូវមានការកត់ត្រាឱ្យបានច្បាស់លាស់ រាល់ពេលមានចំណាយនៅក្នុងក្រុមហ៊ុន។
- គ្រប់គ្រងចំណូលរបស់ក្រុមហ៊ុន ៖ ត្រូវមានការកត់ត្រាឱ្យបានច្បាស់លាស់ត្រឹមត្រូវ រាល់ពេលមានចំណូលនៅក្នុងក្រុមហ៊ុន។
- គ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន៖ ត្រូវមើលការខុសត្រូវនិងថែរក្សាទ្រព្យសម្បត្តិផ្សេងៗ របស់ក្រុមហ៊ុនឱ្យបានល្អកុំឱ្យមានការបាត់បង់ ឬក៏ខូចខាតដោយប្រការណាមួយ។
- រៀបចំដំឡើងរបាយការណ៍ហិរញ្ញវត្ថុ៖ គឺត្រូវធ្វើរបាយការណ៍សំខាន់ៗ៣មានដូចខាងក្រោម

  - តារាងតុល្យការ (Balance Sheet) គឺជារបាយការណ៍ហិរញ្ញវត្ថុមួយប្រភេទដែលបង្ហាញពីប្រភពមូលនិធិនិងការប្រើប្រាស់មូលនិធិរបស់ក្រុមហ៊ុន នៅក្នុងពេលជាក់លាក់មួយ។ វាបង្ហាញពីស្ថានភាពរបស់ទ្រព្យអសកម្ម ឬបំណុល ដើមទុនរបស់ម្ចាស់កម្មសិទ្ធិ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន។

**សមីការគណនេយ្យគឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធគណនេយ្យ៖**

ទ្រព្យសកម្ម = បំណុលទ្រព្យអកម្ម + មូលធនរបស់ម្ចាស់កម្មសិទ្ធិ

Assets = Liabilities + Owner's Equity

  - របាយការណ៍លទ្ធផល (Income Statement) គឺជាជារបាយការណ៍ហិរញ្ញវត្ថុមួយប្រភេទដែលរៀបចំឡើងបង្ហាញ ពីលទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន នៅក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ។ របាយការណ៍លទ្ធផល បង្ហាញពីស្ថានភាពចំណូលចំណាយ ប្រាក់ចំណេញសុទ្ធ និងការ
    បែកចែកប្រាក់ចំណេញរបស់ក្រុមហ៊ុន ថាតើក្រុមហ៊ុនអនុវត្តបានដូចម្តេចខ្លះ ក្នុងរយៈពេលកន្លងមក។
  - របាយការណ៍លំហូរសាច់ប្រាក់(Statement of Cash Flows)ធ្វើសមាហរណកម្មព័ត៌មាននៅលើតារាងតុល្យការ និងរបាយការណ៍លទ្ធផល។ វាបង្ហាញពីផលប៉ះពាល់លើលំហូរសាច់ប្រាក់សុទ្ធរបស់ក្រុមហ៊ុន និងបម្រែបម្រួលសមាសធាតុផ្សេងៗ នៅក្នុងតារាងតុល្យការ។

- ការចំណាយទៅសម្ភារៈផ្គត់ផ្គង់និងចំណាយផ្សេងៗនៅក្នុងក្រុមហ៊ុន។
- ការផ្សះផ្សាសាច់ប្រាក់ របាយការណ៍អតិថិជន និងព័ត៌មានទូទៅ។

**៣.២.២ ការកត់ត្រាចំណូលចំណាយរបស់ក្រុមហ៊ុន**

នៅក្នុងប្រតិបត្តិការក្រុមហ៊ុនដំណើរការទៅមុខទៀត ដូច្នេះក្រុមហ៊ុន Smart Axiata ចំណូល និងចំណាយពិតជាមានសារៈសំខាន់ណាស់ដើម្បីឱ្យក្រុមហ៊ុនអាច Smart Axiata បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការកត់ត្រារបស់គណនេយ្យករ។ ដើម្បីឱ្យចំណូល និងចំណាយមានភាពត្រឹមត្រូវគណនេយ្យករបានអនុវត្តដូចខាងក្រោម៖

**ក.រៀបចំរបាយការណ៍ចំណូល និងចំណាយប្រចាំខែ**

គណនេយ្យករ មានតួនាទីរៀបចំរបាយការណ៍ប្រចាំខែមានដូចជា៖ ការដកប្រាក់ការ ដាក់ប្រាក់ចំណាយលើការទិញសម្ភារៈផ្គត់ផ្គង់ ចំណាយប្រតិបត្តិការ និងចំណាយលើប្រាក់ខែបុគ្គលិកជាដើម។

**ខ. គ្រប់គ្រងលុយកុំឱ្យបាត់**

គណនេយ្យករ មានតួនាទីគ្រប់គ្រងលុយធ្វើយ៉ាងណាកុំឱ្យលុយបាត់បង់ ជាដាច់ខាតក្រុមហ៊ុនមានការចាត់ចែងច្បាស់លាស់ ចំពោះការគ្រប់គ្រងថវិកាចំណាយដែល គណនេយ្យករបានប្រមូលពីអតិថិជន ឬបានចំណាយលើចំណាយប្រតិបត្តិការជាដើមហើយការ ដោយធនាគារធ្វើការផ្ទៀងផ្ទាត់នូវរបាការណ៍ចំណូលធ្វើបែបនេះ ទើបការគ្រប់គ្រងលុយរបស់ក្រុមហ៊ុនមានភាពច្បាស់លាស់ និងអាចជឿទុកចិត្តបាន។

**៣.២.៣ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន**

ចំពោះគណនេយ្យករ ក្រុមហ៊ុនបានបែងចែកការងារជាច្រើន ដល់គណនេយ្យករទាក់ទងនឹងការថែរក្សាសេវាកម្មហិរញ្ញវត្ថុគណនេយ្យ ការកត់ត្រាសកម្មភាពពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីបំពេញតាមតម្រូវការច្បាប់ និងគាំទ្រដល់ប្រតិបត្តិការក្នុងក្រុមហ៊ុន។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គឺជាតួនាទីដ៏សំខាន់បំផុតរបស់គណនេយ្យករ ព្រោះថារបាយការណ៍ហិរញ្ញវត្ថុ គឺជាភស្តុតាងដ៏ចាំបាច់បំផុតសម្រាប់ក្រុមហ៊ុនក្នុងការដំណើរទៅមុខ និងការវិនិយោគពីសំណាក់អ្នកវិនិយោគនិងអ្នកប្រើប្រាស់ខាងក្រៅ និងឱ្យក្រុមហ៊ុនដឹងពីស្ថានភាពជាក់ស្តែងរបស់ក្រុមហ៊ុនថាចំណេញ ឬខាត។ ដូច្នេះ គណនេយ្យករមានតួនាទីដូចខាងក្រោម៖

- ធ្វើរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ចំណេញខាត របាយការណ៍តុល្យការ និងរបាយការណ៍សង្ខេបឱ្យទាន់ពេលវេលា។
- រៀបចំរបាយការណ៍លទ្ធផលប្រចាំខែដូចជា ព័ត៌មានលម្អិតប្រាក់ចំណូល និងចំណាយផលប័ត្រប្រាក់បញ្ញើវេលា និងផលប័ត្រកម្ចី។

ដើម្បីឱ្យរបាយការណ៍ហិរញ្ញវត្ថុមួយ មានភាពត្រឹមត្រូវនិងច្បាស់លាស់ ហើយស្របតាមស្តង់ដារគណនេយ្យគណនេយ្យករ មានតួនាទីសំខាន់មួយចំនួនទៀតដូចខាងក្រោម៖

❖ ពន្ធ (Taxation)

នៅក្នុងក្រុមហ៊ុន Smart Axiata តែងតែធ្វើការប្រកាសពន្ធរៀងរាល់ចុងឆ្នាំទៅលើពន្ធចំនួន ដូច្នេះហើយ គណនេយ្យករមានតួនាទីក្នុងការរៀបចំរបាយការណ៍ ដោយធ្វើការគណនារកលទ្ធផលចំណូល និងចំណាយ ដើម្បីយកទិន្នន័យនោះ ទៅធ្វើការគណនារកទឹកប្រាក់សម្រាប់ធ្វើការប្រកាសពន្ធ ទៅតាមប្រភេទពន្ធសរុបនីមួយៗដែលបានកំណត់។

❖ ធ្វើផែនការ និងរៀបចំថវិការ (Planning and Budget)

នៅក្នុងក្រុមហ៊ុន Smart Axiata មានការរៀបចំថវិការដើម្បីទុកសម្រាប់ចំណាយទៅតាមផ្នែកនីមួយៗ ក៏ដូចជា តម្រូវការផ្សេងៗរបស់ក្រុមហ៊ុនផងដែរ ព្រោះការធ្វើផែនការអាចឱ្យក្រុមហ៊ុនដឹងពីស្ថានភាពបច្ចុប្បន្នបានថាចំណេញឬខាត និងងាយស្រួលក្នុងការចំណាយផ្សេងៗ ប្រកបដោយប្រសិទ្ធភាព។ ហេតុដូចនេះ គណនេយ្យករ មានតួនាទីក្នុងការធ្វើផែនការ និងរៀបចំថវិការទៅតាមការកំណត់របស់ធនាគារដូចជា ថវិការសម្រាប់ចំណាយ ទៅលើប្រាក់ខែបុគ្គលិក ថវិការសម្រាប់ចំណាយទៅលើសម្ភារៈផ្គត់ផ្គង់ ថវិកាសម្រាប់ចំណាយទៅលើការបង់ពន្ធ និងរៀបចំថវិកាសម្រាប់ចំណាយទៅលើដំណើរការផ្សេងៗរបស់ក្រុមហ៊ុន។

### ៣.២.៤ ការរៀបចំរបាយការណ៍ចំណេញ-ខាតរបស់ក្រុមហ៊ុន

សម្រាប់អាជីវកម្មខ្នាតតូច ទោះបីជាអ្នកមិនត្រូវការខ្ចីទុនបន្ថែមពីគ្រឹះស្ថានហិរញ្ញវត្ថុ ក៏អ្នកនៅតែត្រូវការរបាយការណ៍ហិរញ្ញវត្ថុមួយចំនួន សម្រាប់ជួយអ្នកក្នុងការសម្រេចចិត្តក្នុងអាជីវកម្មផងដែរ។ ហិរញ្ញវត្ថុ គឺជាផ្នែកដ៏សំខាន់នៅក្នុងអាជីវកម្ម ហើយគេប្រើប្រព័ន្ធគណនេយ្យ សម្រាប់គ្រងគ្រងទិន្នន័យហិរញ្ញវត្ថុទាំងអស់របស់អាជីវកម្មនោះ។ របាយការណ៍ចំណេញខាត គឺជារបាយការណ៍មួយសំខាន់បំផុត ក្នុងចំណោមរបាយការណ៍ផ្សេងទៀត។ ជាភាសាអង់គ្លេសគេហៅវាថា Income Statement ឬ Profit and Loss Statement។ នៅក្នុងរបាយការណ៍នេះ បង្ហាញអំពីប្រាក់ចំណូលោ និងចំណាយរបស់អាជីវកម្មមួយ ហើយទូទាត់គ្នាដើម្បីរកលទ្ធផលចំណេញឬខាតនៅក្នុងប្រតិបត្តិការ អាជីវកម្មនាពេលវេលាជាក់លាក់ណាមួយ(មួយខែ មួយត្រីមាស ឬមួយឆ្នាំ)។

### ៣.២.៥ ការបិទបញ្ជីរបស់ក្រុមហ៊ុន

ការបិទជាតុ គឺជាជាតុទិនានុប្បវត្តិដែលត្រូវបានធ្វើឡើង នៅចុងបញ្ចប់នៃរយៈពេលគណនេយ្យដែលផ្ទេរសមតុល្យគណនីបណ្តោះអាសន្នទៅគណនីអចិន្ត្រៃយ៍។ ការបិទជាតុ គឺផ្អែកលើសមតុល្យគណនីនៅក្នុងតុល្យភាពនៃការសាកល្បងដែលត្រូវបានកែសម្រួល។ នៅក្នុងក្រុមហ៊ុន Smart Axiata គណនេយ្យករធ្វើការបិទបញ្ជីនៅ រៀងចុងការិយបរិច្ឆេទដោយការបិទបញ្ជីមានបួនជំហានដូចខាងក្រោម៖

- Close Revenue to Income Summary បិទគណនីចំណូល ដោយផ្ទេរសមតុល្យខាងឥណពន្ធចូលទៅក្នុងគណនីលទ្ធផលខាងឥណទាន។
- Close Expense to Income Summaryបិទគណនីចំណាយ ដោយផ្ទេរសមតុល្យខាងឥណទានចូលទៅក្នុងគណនីលទ្ធផលខាងឥណពន្ធ ។

- Close Income Summary to Capitalបិទគណនីលទ្ធផលដោយផ្ទេរសមតុល្យចូលទៅក្នុងគណនីមូលធនទ្រព្យម្ចាស់ ។
- Close Owner`s Draw to Capitalបិទគណនី ការដកប្រាក់របស់ថៅកែដោយផ្ទេរសមតុល្យឥណទានចូលទៅគណនីមូលធនទ្រព្យម្ចាស់ខាងឥណពន្ធ ។

## ៣.៣ សារៈសំខាន់របស់គណនេយ្យករ ក្នុងក្រុមហ៊ុន Smart

គណនេយ្យករគឺមានសារៈសំខាន់សម្រាប់អាជីវកម្មដូចបុគ្គលិកប្រតិបត្តិការរបស់ខ្លួន។ អ្នកត្រូវការបុគ្គលិក ដើម្បីគ្រប់គ្រងលុយរបស់អ្នក នៅពេលដែលអាជីវកម្មរបស់អ្នករីកចម្រើន។

គណនេយ្យករមានសារៈសំខាន់ ជាការពិតណាស់ គណនេយ្យករជាផ្នែកមួយមិនអាចខ្វះបានទេ មិនថារាជរដ្ឋាភិបាល អាជីវកម្មខ្នាតតូច ឬធំ អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុន សិប្បកម្ម... សុទ្ធតែត្រូវការវា ព្រោះថាគណនេយ្យករអាចយល់ពី របាយការណ៍ហិរញ្ញវត្ថុ (Financial Statement) សម្រាប់ធ្វើការកត់ត្រារបាយការណ៍សំខាន់ៗក្នុងក្រុមហ៊ុន ស្មាត ដូចជា៖

ក. របាយការណ៍តុល្យភាព (Balance Sheet/ Statement of Financial Position)

ខ. របាយការណ៍លទ្ធផល (Income Statement/Statement of Financial Performance)

គ. របាយការណ៍លំហូរសាច់ប្រាក់ (Cash Flow Statement/Statement of Financial Position Change)

ឃ.របាយការណ៍ស្តីពីការប្រែប្រួលមូលធនរបស់ម្ចាស់ហ៊ុន( Statement of Stockholder’s Equity Change)

ង. របាយការណ៍សវនកម្ម (Audit Report/Note to Financial Statement)

- បង្កើតរបាយការណ៍ពី Excel, FundEZ និងកម្មវិធីផ្សេងទៀតតាមតម្រូវការរបស់ក្រុមហ៊ុន
- ជួយនាយកផ្នែកហិរញ្ញវត្ថុជាមួយនឹងកិច្ចការរដ្ឋបាលផ្សេងៗតាមតម្រូវការ ហើយនឹងត្រូវបានចាត់តាំងគម្រោងទាក់ទងនឹងហិរញ្ញវត្ថុតាមកាលកំណត់
- ទទួលខុសត្រូវចំពោះតម្រូវការក្រុមហ៊ុន ដូចជាច្បាប់ចម្លង កញ្ចប់ព័ត៌មាន សៀវភៅណែនាំ និងគម្រោងផ្សេងៗ ទៀតតាមតម្រូវការ
- ជួយរៀបចំសវនកម្មប្រចាំឆ្នាំ រួមទាំងកាលវិភាគដែលត្រូវការទាំងអស់។
- ធានាថារាល់ឯកសារសមស្របដែលទាក់ទងនឹងមុខតំណែងត្រូវបានរៀបចំ រៀបចំ និងរក្សាទុកក្នុងលក្ខណៈទាន់ពេលវេលា
- ប្រកាន់ខ្ជាប់នូវគោលការណ៍ និងនីតិវិធីរបស់ភ្នាក់ងារ និងបទប្បញ្ញត្តិទីក្រុង ខោនធី រដ្ឋ និងសហព័ន្ធទាំងអស់។
- ចូលរួមការប្រជុំ និងការបណ្តុះបណ្តាលទាំងអស់តាមតម្រូវការ

គណនេយ្យករ នឹងធ្វើការជាផ្នែកដ៏សំខាន់នៃក្រុមហ៊ុន ហើយនឹងទទួលខុសត្រូវ ជាចម្បងចំពោះកិច្ចការមួយចំនួនខាងក្រោម ហើយនឹងធ្វើការបម្រុងទុកលើអ្នកផ្សេងទៀតក្នុងក្រុមហ៊ុន ស្មាតដូចជា៖

- ដំណើរការវិក្កយបត្រ/វិក្កយបត្រ A/P ទាំងអស់ ដើម្បីធានាថាការអនុម័តត្រឹមត្រូវ និងឯកសារបម្រុងទុកត្រូវបានទទួលដោយអនុលោមតាមគោលការណ៍លទ្ធកម្មរបស់ Emerge

- រៀបចំការត្រួតពិនិត្យ A/P រៀងរាល់សប្តាហ៍ និងចែកចាយតាមតម្រូវការ
- ត្រួតពិនិត្យប្រអប់អ៊ីមែលស្នើសុំពិនិត្យ និងដំណើរការសំណើពិនិត្យទាំងអស់ ដោយផ្តល់អាទិភាពលើសំណើ "ប្រញាប់ប្រញាល់" ទាក់ទងនឹងការបំពេញតម្រូវការរបស់អ្នកចូលរួម ដែលអាចជាប្រចាំថ្ងៃ
- រក្សាឯកសារអ្នកលក់ បញ្ជីអ្នកលក់ និងស្ថានភាពលើកលែងពន្ធរដ្ឋ Az សម្រាប់អ្នកលក់ទាំងនោះ ដោយបំពេញវិញ្ញាបនបត្រសមស្រប និងបញ្ជូនបន្តទៅអ្នកលក់។
- បម្រើជាអ្នកលក់ចម្បង និងទំនាក់ទំនងបុគ្គលិកសម្រាប់ A/P និងពិនិត្យបញ្ហា។ ទទួលខុសត្រូវលើការស្រាវជ្រាវ និងដោះស្រាយបញ្ហាទាំងនោះ
- សម្របសម្រួលព័ត៌មាន 1099 សម្រាប់អ្នកលក់ទាំងអស់ និងដំណើរការ 1099 ឯកសារនៅចុងឆ្នាំ
- ទទួលខុសត្រូវចំពោះការចែកចាយ និងតាមដានប័ណ្ណឥណទានរបស់ភ្នាក់ងារទាំងអស់ ដោយភ្ជាប់ជាមួយគោលការណ៍
- ពិនិត្យសំណើសំណងទាំងអស់ និងសំណើរបស់បុគ្គលិកផ្សេងទៀតសម្រាប់ភាពត្រឹមត្រូវ និងឯកសារបម្រុងទុកត្រឹមត្រូវ និងការសរសេរកូដ
- ផ្តល់ការបម្រុងទុកសម្រាប់ដំណើរការប្រាក់បញ្ញើធនាគារអេឡិចត្រូនិកនៅគុខាងមុខ
- រៀបចំប្រាក់បញ្ញើតាមធនាគារដោយដៃនៅពេលចាំបាច់ជាសាច់ប្រាក់ ឬនៅពេលដែលប្រាក់បញ្ញើមិនអាចធ្វើឡើងតាមអេឡិចត្រូនិក
- ត្រួតពិនិត្យប្រតិបត្តិការធនាគារដែលចូលមក និងធានាថាឯកសារបម្រុងទុកត្រូវបានរក្សាទុក ហើយរាល់ការដាក់ប្រាក់ ឬប្រតិបត្តិការ ACH ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីគណនេយ្យជាមួយនឹងការសរសេរកូដត្រឹមត្រូវ។
- ប្រគល់ប្រាក់បញ្ញើដោយដៃទៅធនាគារនៅពេលចាំបាច់
- រៀបចំការផ្ទៀងផ្ទាត់ធនាគារ (ជាពិសេសសម្រាប់បុគ្គលិកដែលមិនដាក់ប្រាក់)
- ផ្ទៀងផ្ទាត់គណនីសៀវភៅទូទៅតាមការចាំបាច់
- តាមដាន និងផ្ទៀងផ្ទាត់ប្រតិបត្តិការប័ណ្ណអំណោយ និងមូលនិធិបោកអ៊ុតនៅក្នុងកំណត់ហេតុរៀងៗខ្លួន ហើយបង្កើតរបាយការណ៍ប្រចាំខែជាមួយនឹងគណនេយ្យ ដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់អ្វីដែលប័ណ្ណអំណោយ និងមូលនិធិបោកគក់នៅតែមានក្នុងដៃសម្រាប់ប្រើក្នុងសវនកម្មផ្ទៃក្នុង
- សម្របសម្រួលសវនកម្មផ្ទៃក្នុងនៃកាតអំណោយជាមួយបុគ្គលិក
- ដំណើរការជាតុទិនានុប្បវត្តិទៀងទាត់ និងប្រតិបត្តិការបញ្ជីឈ្មោះទូទៅផ្សេងទៀត លើមូលដ្ឋានបង្គរដោយអនុលោមតាមគោលការណ៍គណនេយ្យដែលទទួលយកជាទូទៅនិងស្តង់ដាររដ្ឋាភិបាល
- ជួយជាមួយនឹងការចេញវិក្កយបត្រ Grant និងការចំណាយលើការស្រាវជ្រាវទាក់ទងនឹងថវិកាកម្មវិធី
- ផ្តល់ការគាំទ្រ ជាមួយនឹងការបញ្ចូលទិន្នន័យទាក់ទងនឹងការផ្តល់មូលនិធិចូល ដោយភាពជាដៃគូជាមួយនាយកដ្ឋានអភិវឌ្ឍន៍ តាមតម្រូវការ
- ផ្តល់របាយការណ៍ពីប្រព័ន្ធគណនេយ្យ នៅពេលដែលត្រូវការដោយនាយក ឬអ្នកគ្រប់គ្រង។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្នុងក្រុមហ៊ុន Smart Axiata បន្តដំណើរជោគជ័យជាង ១៤ ឆ្នាំតាមរយៈដំណើរការល្អឥតខ្ចោះប្រកបដោយនិរន្តរភាព។




**ភ្នំពេញ - ថ្ងៃទី ១៣ មិនា ឆ្នាំ២០២៣៖** ក្រុមហ៊ុន Smart Axiata ដែលជាក្រុមហ៊ុនទូរគមនាគមន៍ឈានមុខគេនៅកម្ពុជា បានប្រារព្ធខួបគម្រប់ ១៤ ឆ្នាំរបស់ក្រុមហ៊ុនកាលពីខែកុម្ភៈកន្លងមក។ ប្រតិបត្តិករទូរស័ព្ទចល័តមួយនេះ បានរំលឹកឡើងវិញ ពីសមិទ្ធិផលរបស់ក្រុមហ៊ុននៅក្នុងវិស័យទូរគមនាគមន៍កម្ពុជា រួមមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួន ចំពោះកិច្ចប្រតិបត្តិការប្រកបដោយនិរន្តរភាព ដែលឆ្លុះបញ្ចាំងពីគុណតម្លៃស្នូលរបស់ក្រុមហ៊ុន។

ជាមួយនឹងចក្ខុវិស័យដើម្បីក្លាយខ្លួន ជាទូរគមនាគមន៍លេខមួយនៅកម្ពុជា ភាពជោគជ័យរបស់ក្រុមហ៊ុន Smart តែងតែផ្តោតសំខាន់ក្នុងការចូលរួមចំណែកការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដើម្បីបង្កើតជាប្រយោជន៍រួមយូរអង្វែង ដល់ប្រជាជន និងសហគមន៍ទូទាំងប្រទេសកម្ពុជា តាមរយៈការផ្សារភ្ជាប់ទំនាក់ទំនង និងដំណោះស្រាយឌីជីថលពោរពេញដោយភាពច្នៃប្រឌិត។

### ៤.១ ការវិភាគលើចំណុចខ្លាំង

បន្ទាប់ពីធ្វើការស្រាវជ្រាវអំពីសារៈសំខាន់របស់គណនេយ្យករនៅក្នុងក្រុមហ៊ុន **ស្មាត អាស្យាតា** កន្លងមកបានស្តែងឱ្យ យើងឃើញនូវចំណុចខ្លាំងរបស់គណនេយ្យករដូចជា៖

- បញ្ចូលទិន្នន័យ បើកប្រាក់ពីឯកសារវេណទានទៅក្នុងប្រព័ន្ធកុំព្យូទ័រ នៅពេលដែលមានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ។
- ចុះបញ្ជីគណនេយ្យ ផ្អែកតាមសក្ខីបត្រស្របច្បាប់។

- បញ្ចូលទិន្នន័យក្នុងកម្មវិធីកុំព្យូទ័រតាមប្រតិបត្តិការសេដ្ឋកិច្ចកើតឡើងប្រចាំថ្ងៃដោយ និងត្រឹមត្រូវតាមប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុន។
- ត្រួតពិនិត្យផ្ទៀងផ្ទាត់នូវរាល់សមតុល្យសាច់ប្រាក់ ដែលមានដាក់ស្តែងជាមួយបេឡាធិការធៀបនឹងសមតុល្យដែលមានក្នុងបញ្ជីរៀងរាល់ថ្ងៃ។
- ការដាក់ប្រាក់ ឬដកប្រាក់ និងការសងប្រាក់។
- កត់ត្រាប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃរបស់ក្រុមហ៊ុន៖ កត់ត្រាការលក់ចេញ ការទិញចូល និងចំណាយផ្សេងៗទៀត។
- គ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន ៖ ត្រូវមានការកត់ត្រាឱ្យបានច្បាស់លាស់ រាល់ពេលមានចំណាយនៅក្នុងក្រុមហ៊ុន។
- គ្រប់គ្រងចំណូលរបស់ក្រុមហ៊ុន ៖ ត្រូវមានការកត់ត្រាឱ្យបានច្បាស់លាស់ត្រឹមត្រូវ រាល់ពេលមានចំណូលនៅក្នុងក្រុមហ៊ុន។
- គ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន៖ ត្រូវមើលការខុសត្រូវ និងថែរក្សាទ្រព្យសម្បត្តិផ្សេងៗរបស់ក្រុមហ៊ុនឱ្យបានល្អកុំឱ្យមានការបាត់បង់ ឬក៏ខូចខាតដោយប្រការណាមួយ។
- រៀបចំដំឡើងរបាយការណ៍ហិរញ្ញវត្ថុ៖ គឺត្រូវធ្វើរបាយការណ៍សំខាន់ៗ
- បានត្រួតពិនិត្យផ្ទៀងផ្ទាត់នូវរាល់សមតុល្យសាច់ប្រាក់ ដែលមានដាក់ស្តែងជាមួយបេឡាធិការធៀបនឹងសមតុល្យដែលមានក្នុងបញ្ជីជារៀងរាល់ថ្ងៃ
- ការចំណាយទៅសម្ភារៈផ្គត់ផ្គង់និងចំណាយផ្សេងៗនៅក្នុងក្រុមហ៊ុន។
- ការផ្ទេរៈផ្សាសាច់ប្រាក់ របាយការណ៍អតិថិជន និងព័ត៌មានទូទៅ។
- មានការគ្រប់គ្រងយ៉ាងហ្មត់ចត់ទៅលើការគ្រប់គ្រងលុយមិនឱ្យមានការបាត់បង់ជាដាច់ខាត
- មានការរៀបចំផែនការ ការរៀបចំថវិកា (Planning and Budget) បានត្រឹមត្រូវ
- មានការធ្វើការបិទបញ្ជីរៀងរាល់ចុងការិយបរិច្ឆេទបានទាន់ពេលវេលានិងច្បាស់លាស់ល្អ។

**៤.២ ការវិភាគលើចំណុចខ្សោយ**

ឆ្លងតាមការវិភាគលើចំណុចខ្លាំងលើតួនាទីរបស់គណនេយ្យករនៅក្រុមហ៊ុន smart Axiata រួចមកយើងក៏ឃើញមានចំណុចខ្សោយមួយចំនួនរបស់ក្រុមហ៊ុនមួយនេះផងដែរ ដែលមានដូចខាងក្រោម៖

- ការប្រើប្រាស់នូវបច្ចេកវិទ្យា ក៏ដូចជាការប្រើប្រាស់នូវភាសាបរទេសរបស់គណនេយ្យករនៅមានកម្រិតនៅឡើយ។
- ការកត់ត្រានៅមានភាពយឺតយ៉ាវពេលមានប្រតិបត្តិការច្រើន។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងទៅលើលទ្ធផល នៃការសិក្សាស្រាវជ្រាវកន្លងមក លើប្រធានបទ "សារៈសំខាន់របស់គណនេយ្យករ ក្នុងក្រុមហ៊ុនសេវាកម្ម Smart Axiata" យើងអាចសន្និដ្ឋានបានថា ការអនុវត្តន៍ការងាររបស់គណនេយ្យករ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុន Smart ដែលជាសរសៃឈាមយ៉ាងសំខាន់បំផុតសម្រាប់ការធ្វើរបាយណ៍ ការរាយការរបាយណ៍ ដែលទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ។ គណនេយ្យករមានការយល់ដឹងខ្ពស់អំពីតួនាទីរបស់ខ្លួនដែលត្រូវធ្វើ ព្រោះក្រុមហ៊ុនបានបែកចែកការងារច្បាស់លាស់ និងសមស្របតាមគោលការណ៍របស់ក្រុមហ៊ុន ធ្វើឱ្យគណនេយ្យករអាចបំពេញតួនាទីយ៉ាងរលូន ទាន់ពេលវេលា និងមានភាពត្រឹមត្រូវ។ ពិតណាស់គណនេយ្យករ គឺជាផ្នែកមួយដែលសំខាន់ សម្រាប់ក្រុមហ៊ុនសេវាកម្មទូរគមនាគមន៍របស់ Smart Axiata ព្រោះគណនេយ្យករអាចដឹងពីស្ថានភាពរបស់ក្រុមហ៊ុនច្បាស់ ក្នុងការបម្រើសេវាដល់អតិថិជន។ ដោយសារតែគណនេយ្យករ គឺជាអ្នកដែលកត់ត្រាប្រតិបត្តិការរបស់ក្រុមហ៊ុន Smart ដូចច្នេះ មិនថាការដំឡើងរបាយការណ៍សំខាន់ៗរបស់ក្រុមដូចជា របាយការណ៍តុល្យការ(Balance Seet) របាយការណ៍លទ្ធផល(Income Statements )របាយការណ៍លំហូរសាច់ប្រាក់(Cash Flow Statements ) របាយការណ៍ស្តីពីការបម្រែបម្រួលមូលធនរបស់ម្ចាស់ហ៊ុន( Statement of Stockholder`s Equity Chane ) និងរបាយការណ៍សវនកម្ម (Audit Report /Note to Financial Statement)។ ទាំងនេះហើយគឺជាភាពសំខាន់របស់គណនេយ្យករ ដែលអាចធ្វើឱ្យគណនេយ្យករមានភាពយល់ដឹងពីការចំណាយ និងចំណូលរបស់ក្រុមហ៊ុន Smart Axiata បានយ៉ាងល្អ និងធ្វើឱ្យមានភាពរលូនក្នុងផ្នែកហិរញ្ញវត្ថុ ក្នុងកំឡុងពេលក្រុមហ៊ុនប្រើប្រាស់ទន់ដើម្បីរកស៊ី ឬវិនិយោគជាមួយក្រុមហ៊ុនដទៃផ្សេងទៀត។

សរុបរួមមក សារៈសំខាន់របស់គណនេយ្យករពិតជាធ្វើឱ្យក្រុមហ៊ុនសេវាកម្ម Smart Axiata មានភាពល្អប្រសើរប្រកបដោយសុវត្ថិភាពលើផ្នែកហិរញ្ញវត្ថុដែលជាសរសៃឈាមរបស់ក្រុមហ៊ុនយ៉ាងសំខាន់។ មិនតែប៉ុណ្ណោះ គណនេយ្យករអាចធ្វើឱ្យក្រុមហ៊ុនមានសន្ទុះកើនឡើងនូវប្រាក់ចំណេញ ពីការផ្តល់សេវាកម្មពីសំណាក់អតិថិជនទាំងក្នុងប្រទេស និងក្រៅប្រទេសតាមរយៈការរៀបចំរបាយការណ៍យ៉ាងច្បាស់លាស់របស់គណនេយ្យករ។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ បកស្រាយ និងសន្និដ្ឋានជុំវិញប្រធានបទ «សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុនសេវាកម្ម Smart Axiata » ដោយប្រើវិធីសាស្ត្រ ទិន្នន័យចម្បង ទិន្នន័យបន្ទាប់បន្សំ និង ការវិភាគលើឯកសារផ្សេងៗដែលទាក់ទងនឹងប្រធានបទ រយៈពេលកន្លងមកនេះបង្ហាញឱ្យឃើញថា សារៈសំខាន់របស់គណនេយ្យករក្នុងក្រុមហ៊ុនសេវាកម្ម Smart Axiata គឺពិតជាធ្វើឱ្យក្រុមហ៊ុនមានភាពរីកចម្រើនទាំងអស់នៃផ្នែកគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ និងបញ្ជីផ្សេងៗដែលមានការពាក់ព័ន្ធនឹងក្រុមហ៊ុនដូចជាការចេញវិក័យបត្រផ្សេងៗ។ ទន្ទឹមនឹងការសិក្សាលើប្រធានបទខាងលើនេះដែរទោះគណនេយ្យករ

មានភាពសំខាន់យ៉ាងខ្លាំង ប៉ុន្តែគណនេយ្យករនៅតែមានចំណុចខ្វះខាតមួយចំនួនតូច ដែលធ្វើការកែលម្អ ដូច្នេះ ក្រុមយើងខ្ញុំសូមធ្វើការផ្តល់នូវយោបល់បន្ថែមទៅលើចំណុចខ្វះខាតដូចជា៖

- គណនេយ្យករ គួរតែមានការចូលរួមវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងភាសាបរទេស និងបច្ចេកវិទ្យាបន្ថែមដើម្បីពង្រឹងស្តង់ដាការងារឱ្យកាន់តែប្រសើរឡើង។
- គណនេយ្យករគប្បីបំពេញតួនាទីឱ្យបានទាន់ពេលវេលាជៀសវាងការកកស្ទះនូវការងារ។

# ឯកសារយោង

# ឯកសារយោង

1. ដកស្រង់ចេញពីសៀវភៅមូលដ្ឋានគ្រឹះគណនេយ្យហិរញ្ញវត្ថុ របស់វិទ្យាស្ថានវ៉ាន់ដា ក្នុងឆ្នាំ២០១៨

2. ដកស្រង់ពីវចនានុក្រមខ្មែររបស់សម្តេច សង្ឃរាជ ជួនណាត

3. ដកស្រង់ចេញពីសៀវភៅសារណារបស់សិស្សច្បងនៃ វិស្ថាន វ៉ាន់ដា បោះពុម្ពក្នុងឆ្នាំ២០២០

4. ដកស្រង់ចេញពី(ស៊ីមវិចិត្រet,ក្នុងឆ្នាំ 2009)

5. តាមសៀវភៅរបស់លោក Rabert Fmery,ក្នុងឆ្នាំ 1998

5. ដកស្រង់ចេញពី Page សកលវិទ្យាល័យ បៀលប្រាយ (Accounting Principle)

6. ដកស្រង់ និងបកប្រែចេញពីសៀវភៅ Summa de arithmetica របស់លោក Pacioli ជនជាតិ អ៊ីតាលី ក្នុងឆ្នាំ 1494.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ





*សកម្មភាពការចុះស្រាវជ្រាវ និងសាកសួរពីព័ត៌មានក្នុងក្រុមហ៊ុន ស្មាត ដោយផ្ទាល់ នៅសាខាទួលទំពូង*